សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Science Economiques

Royal University of Law and Economics

# សារណាបញ្ចប់ការសិក្សា

# ចំណាត់ការសំណុំរឿង

# ព្រហ្មទណ្ឌរបស់អង្គការអយ្យការ

ស្រាវជ្រាវពីថ្ងៃទី០២ ខែមេសា ឆ្នាំ២០១៨ ដល់ ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១៨


តាក់តែងឡើងដោយ

និស្សិតឈ្មោះ៖ **លោក ឈុំ លីហួរ**

**កញ្ញា កែវ គីមស៊ីង**

សាស្ត្រាចារ្យណែនាំ

**លោក ហ៊ាង ឡេង**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី១៨

ឆ្នាំចូលរៀន ២០១៤

ឆ្នាំសរសេរសារណា ២០១៨

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ឈុំ លីហួរ** និងនាងខ្ញុំឈ្មោះ **កែវ គីមស៊ីន** ជានិស្សិតផ្នែកនីតិសាស្ត្រនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា២០១៧-២០១៨ ជំនាន់ទី១៨។

ជាដំបូងខ្ញុំបាទ/នាងខ្ញុំ ទាំងពីរនាក់ សូមថ្លែងអំណរគុណចំពោះ លោកឪពុក អ្នកម្តាយ ដែលបានបង្កើតរូបកាយកូន និងចិញ្ចឹមបីបាច់ថែរក្សា អប់រំទូន្មាន ឧបត្ថម្ភរូបកូនគ្រប់បែបយ៉ាងតាំងពីតូចដល់ធំ ទាំងកម្លាំងកាយ ទាំងកម្លាំង ចិត្តមិនគិតពីការនឿយហត់របស់លោកទាំងពីរនោះឡើយ និងបានឱ្យកូនបានរៀនសូត្រមានចំណេះដឹង រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រដោយជោគជ័យ។

គុណូបការៈយ៉ាងធំអនេក និងវិសេសវិសាលថ្លៃថ្លាបំផុត ដែលមិនអាចកាត់ថ្លៃបានរបស់លោកអ្នកមានគុណទាំងពីរ ដែលជាម្លប់ដ៏ប្រពៃត្រជាក់ត្រជុំសម្រាប់កូនគ្រប់ៗរូប មានទំហំធំធេងរកអ្វីប្រៀបផ្ទឹមពុំបានឡើយ។ ទង្វើរបស់លោកទាំងពីរ ធ្វើឱ្យកូនៗចងចាំជានិច្ចគ្មានថ្ងៃបំភ្លេចបាន ហើយនឹងស្ថិតក្នុងដួងព្រលឹងរបស់កូនៗជារៀងដរាបគ្មានថ្ងៃសូន្យនោះឡើយ។

យើងខ្ញុំទាំងពីរនាក់ ក៏សូមថ្លែងអំណរគុណចំពោះ សាកលវិទ្យាធិការ សាកលវិទ្យាធិការរងលោក លោកស្រី និងសាស្ត្រាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំយកចិត្តទុកដាក់ក្នុងការផ្តល់នូវពុទ្ធិល្អៗយ៉ាងពិតប្រាកដ សម្រាប់ជាប្រទីបបំភ្លឺជីវិតយើងខ្ញុំនៅក្នុងថ្នាក់បរិញ្ញាបត្រនេះ។

ជាពិសេសយើងខ្ញុំសូមថ្លែងអំណរគុណ ចំពោះលោកសាស្ត្រាចារ្យ **ហ៊ាង ឡេង** ដែលជាសាស្ត្រាចារ្យណែនាំ ដើម្បីធ្វើឱ្យមាននូវដំណើរការនៃការតាក់តែងសារណានេះឡើង ប្រកបដោយជោគជ័យ។ ជាពិសេសលោកបានចំណាយនូវកម្លាំងកាយ កម្លាំងចិត្ត និងពេលវេលាដ៏មានតម្លៃក្នុងការប្រឹងប្រែងពន្យល់ណែនាំតម្រង់ទិស ផ្តល់ឯកសារពាក់ព័ន្ធនឹងសារណា ផ្តល់អនុសាសន៍ល្អៗ និងជួយកែលម្អចំណុចខ្វះខាតទាំងឡាយ ដើម្បីធ្វើយ៉ាងណាឱ្យសារណាយើងខ្ញុំបានទទួលនូវលទ្ធផលល្អ និងត្រឹមត្រូវ ។

ជាចុងបញ្ចប់ យើងខ្ញុំទាំងពីរនាក់សូមប្រសិទ្ធពរជ័យសិរីបវរជូនដល់ **លោកអ្នកមានគុណទាំងពីរ ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ** ទាំងអស់សូមបានប្រកបតែនឹងព្រះពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ស្ថិតក្នុងបរិបទនៃការកសាងប្រទេសជាតិឡើងវិញលើគ្រប់វិស័យ បន្ទាប់ពីមានមហាវិនាសកម្មដែលកើតឡើង ដោយរបបខ្មែរក្រហមនាពេលកន្លងមកនេះ កម្ពុជាបានជួបប្រទះឧបសគ្គជាច្រើនឥតគណនា។ កម្ពុជាបានចាកចេញពីរបបខ្មែរក្រហមដោយបាតដៃទទេរស្អាត ហើយគ្រប់ហេដ្ឋារចនាសម្ព័ន្ធ ត្រូវបានបំផ្លិចបំផ្លាញស្ទើរតែទាំងស្រុង។ មិនតែប៉ុណ្ណោះ ធនធានមនុស្សដែលបន្សល់ទុកពីសម័យសម្តេច នរោត្តម សីហនុ ក៏ត្រូវបានបាត់បង់អស់ស្ទើរតែរលីងលើគ្រប់វិស័យទាំងអស់ ហើយជាពិសេសលើវិស័យយុត្តាធិការ និងផ្នែកស្ថាប័នអយ្យការតែម្តង។

នៅមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ប្រទេសកម្ពុជាមានរដ្ឋអាជ្ញាចំនួន៣៨នាក់ ហើយចំនួននេះនៅសល់ត្រឹមតែ០៣នាក់ប៉ុណ្ណោះនៅក្រោយថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៩។ ដោយសារតែចំនួនរដ្ឋអាជ្ញាមាននៅសល់តិចតួចពេក ទើបធ្វើឱ្យវិស័យនេះបាត់បង់អានុភាពនៃអំណាច ហើយព្រោះតែមូលហេតុនេះហើយទើបបណ្តាលឱ្យ នយោបាយព្រហ្មទណ្ឌរបស់កម្ពុជានាពេលនោះមានភាពទន់ខ្សោយជាខ្លាំង។

ក្រោមការជួយជ្រោមជ្រែងពីអង្គការសហប្រជាជាតិហៅកាត់ថា "UNTAC" កម្ពុជាបានបង្កើតច្បាប់នីតិវិធីមួយឡើងនៅឆ្នាំ១៩៩៣។ នៅក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់នេះ បានប្រគល់អំណាចឱ្យព្រះរាជអាជ្ញាជាម្ចាស់បណ្តឹងអាជ្ញាអាចធ្វើចោទប្រកាន់ និងបញ្ជូនជនល្មើសទៅតុលាការដើម្បីផ្តន្ទាទោសតាមផ្លូវច្បាប់។ ព្រះរាជអាជ្ញាធ្វើការក្នុងនាមជាបុគ្គលតំណាងឱ្យរដ្ឋ តំណាងឱ្យផលប្រយោជន៍រួមនៃសង្គម ដូច្នេះនៅពេលបានដឹងថាមានបទល្មើសកើតឡើង ព្រះរាជអាជ្ញាគ្មានជម្រើសអ្វីក្រៅពីធ្វើការចោទប្រកាន់បញ្ជូនជនសង្ស័យឱ្យចៅក្រមស៊ើបសួរឡើយ។

កាលពីដំបូង គេនឹកស្មានថាជម្រើសតែមួយមុខ គឺការចោទប្រកាន់ឱ្យបើកការស៊ើបសួររបស់ព្រះរាជអាជ្ញា គឺជាមធ្យោបាយដ៏ល្អបំផុតដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ និងជនជាប់ចោទ។ ក៏ប៉ុន្តែ ដោយសារតែការធ្វើសកម្មភាពដដែលៗរបស់ព្រះរាជអាជ្ញានេះ បានជាធ្វើឱ្យកំណើនរឿងក្តីស៊ើបសួររបស់ចៅក្រមស៊ើបសួរកាន់តែច្រើនឡើងៗពីមួយថ្ងៃទៅមួយថ្ងៃ ហើយរហូតក្លាយជារឿងអយុត្តិធម៌ ចំពោះភាគីជនរងគ្រោះ និងភាគីជនជាប់ចោទទៅវិញ។

ទស្សនៈច្បាប់មួយបានលើឡើងថា "យុត្តិធម៌យឺតយ៉ាវមានន័យថាស្មើអយុត្តិធម៌"។ ប៉ុន្តែក្រោយមករហូតមកដល់ឆ្នាំ២០០៧ ទើបមានដំណោះស្រាយចំពោះកំណើនសំណុំរឿងក្តីស៊ើបសួរនេះត្រូវបានដោះស្រាយបានល្អប្រសើរជាងមុន គឺតាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌថ្មីចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ បានផ្តល់អំណាចឱ្យព្រះរាជអាជ្ញាអាចមានជម្រើសច្រើនជាងមុន គឺអាចធ្វើការតម្កល់រឿងទុកឥតចាត់ការ ឬចោទប្រកាន់ឱ្យបើកការស៊ើបសួរ ឬបញ្ជូនទៅជំនុំជម្រះជាអាទិ៍។ ជម្រើសទាំង

ប៉ុន្មានដែលបានរៀបរាប់នេះមានចែងក្នុងមាត្រា៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ហើយដែលក្រមនេះបានឱ្យឈ្មោះថា "ជម្រើសនៃការចោទប្រកាន់"។ ជម្រើសនៃការចោទប្រកាន់នេះ គឺជាមធ្យោបាយថ្មីមួយចំពោះចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌរបស់ព្រះរាជអាជ្ញា។ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់អំពីវិសាលភាពនៃនីតិវិធីថ្មីនេះ ទើបខ្ញុំបាទ/នាងខ្ញុំ សម្រេចជ្រើសរើសយកប្រធានបទស្តីពី "ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌរបស់អង្គការអយ្យការ" មកធ្វើជាប្រធានបទក្នុងការស្រាវជ្រាវ ដោយផ្តោតសំខាន់ទៅលើការចោទប្រកាន់ និងការតម្កល់រឿងទុកឥតចាត់ការ។ ទន្ទឹមនឹងនេះ ប្រធានបទនេះក៏បានឆ្លងកាត់ការពិគ្រោះពិភាក្សា ផ្តល់យោបល់ និងណែនាំពីសំណាក់លោកសាស្ត្រាចារ្យ មេធាវីក្រឡាបញ្ជី និងបងប្អូនមិត្តនិស្សិតរួមជំនាន់ផងដែរ។

ខ្ញុំបាទ/នាងខ្ញុំ ពិតជាមានសេចក្តីរីករាយយ៉ាងខ្លាំង ដែលបានសរសេរសារណា ស្តីពីចំណាត់ការសំណុំរឿងព្រហ្មទណ្ឌរបស់អង្គការអយ្យការដោយមានសាស្ត្រាចារ្យណែនាំលោក **ហ៊ាន ឡេង** ដែលបានផ្តល់យោបល់ណែនាំ ផ្តល់ឯកសារដល់យើងទាំងពីរនាក់ ដើម្បីអាចសរសេរសារណានេះទៅដោយរលូនបានល្អ។ សង្ឃឹមថាសារណានេះ នឹងក្លាយជាឯកសារស្រាវជ្រាវដល់សិស្ស និស្សិតជំនាន់ក្រោយៗដើម្បីសិក្សាស្រាវជ្រាវពីចំណាត់ការសំណុំរឿងព្រហ្មទណ្ឌរបស់អង្គការអយ្យការ។

បើទោះបីជាមានការខិតខំសិក្សាស្រាវជ្រាវ និងការត្រួតពិនិត្យយ៉ាងហ្មត់ចត់យ៉ាងណាក៏ដោយក៏ការសរសេរសារណានេះ ពិតជាមានចំណុចមួយចំនួនដែលខ្វះខាត ដូចនេះយើងខ្ញុំទាំងពីរនាក់រង់ចាំទទួលការរិះគន់ពីសំណាក់សាស្ត្រាចារ្យ សិស្សនិស្សិតផ្សេងៗទៀតដើម្បីកែលម្អសារណានេះឱ្យកាន់តែមានលក្ខណៈល្អប្រសើរ។

## មាតិកា


**សេចក្តីផ្តើម** ........................................................................................................................................ ១

**ជំពូកទី១ ប្រវត្តិ និងគោលការណ៍សំខាន់នៃអង្គការអយ្យការ** ...................................................................... ៣

**ផ្នែកទី១ ប្រវត្តិស្ថាប័នអយ្យការនៅកម្ពុជា** .................................................................................................. ៣

កការបង្កើតស្ថាប័នអយ្យការអំឡុងឆ្នាំ១៩៣៧ មកទល់ឆ្នាំ១៩៧០ . ............................................................ ៣

ខស្ថាប័នអយ្យការអំឡុងឆ្នាំ១៩៧០ មកទល់ឆ្នាំ១៩៧៥ . .............................................................................. ៤

គស្ថាប័នអយ្យការអំឡុងឆ្នាំ១៩៧៥ មកទល់ឆ្នាំ១៩៧៩ . .............................................................................. ៤

ឃស្ថាប័នអយ្យការអំឡុងឆ្នាំ១៩៧៩ មកទល់ឆ្នាំ១៩៩២ . .............................................................................. ៥

ងស្ថាប័នអយ្យការចាប់តាំងពីឆ្នាំ១៩៩២ មកទល់ឆ្នាំ២០០៧ ......................................................................... ៥

ចស្ថាប័នអយ្យការចាប់តាំងពីឆ្នាំ២០០៧ មកទល់បច្ចុប្បន្ន ............................................................................ ៦

**ផ្នែកទី ២ គោលការណ៍សំខាន់ៗនៃស្ថាប័ន និងចៅក្រមអយ្យការ** .............................................................. ៧

**កថាខណ្ឌទី១គោលការណ៍សំខាន់ៗនៃស្ថាប័នអយ្យការ** . ........................................................................... ៧

កគោលការណ៍ឯកភាព ឬឋានានុក្រម . ............................................................................................... ៧

ខគោលការណ៍ឯករាជ្យ . ...................................................................................................................... ៩

**កថាខណ្ឌទី២ គោលការណ៍សំខាន់ៗនៃចៅក្រមអយ្យការ** ........................................................................... ៩

កគោលការណ៍មិនប្តឹងដឹតចិត្ត . ............................................................................................................ ៩

ខ. គោលការណ៍អវិភាគកម្ម ................................................................................................................... ១០

គគោលការណ៍មិនទទួលខុសត្រូវ . ......................................................................................................... ១០

**ជំពូកទី២ រចនាសម្ព័ន្ធ និងឋានានុក្រមនៃអង្គការអយ្យការ** ......................................................................... ១០

**ផ្នែកទី១ ឋានានុក្រមនៃអង្គការអយ្យការ** ..................................................................................................... ១០

ក រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ .......................................................................................................................... ១០

ខ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ...................................................................................................... ១២

**ផ្នែកទី២ រចនាសម្ព័ន្ធនៃអង្គការអយ្យការ** .................................................................................................. ១២

កអយ្យការអមសាលាដំបូងរាជធានី ខេត្ត . ................................................................................................ ១៣

ខមហាអយ្យការអមសាលាឧទ្ធរណ៍. ............................................................................................................ ១៣

គមហាអយ្យការអមតុលាការកំពូល. ........................................................................................................... ១៤

**ជំពូកទី៣ ចំណាត់ការលើសំណុំរឿងរបស់អយ្យការ** ...................................................................................... ១៤

**ផ្នែកទី១ បណ្តឹងព្រហ្មទណ្ឌ និងបញ្ជីឈ្មោះសៀវភៅនៃសំណុំរឿងព្រហ្មទណ្ឌ** ............................................. ១៤

**កថាខណ្ឌទី១ នីតិវិធីទទួលបណ្តឹងព្រហ្មទណ្ឌ** ............................................................................................. ១៥

កពាក្យបណ្ដឹងទាមទារ និងពាក្យបណ្ដឹងបរិហារដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក... ១៥
ក១ ពាក្យបណ្ដឹងទាមទារ.......................................................................................... ១៥
ក២ ពាក្យបណ្ដឹងបរិហារ.......................................................................................... ១៦
ខ .ពាក្យបណ្ដឹង និងពាក្យបណ្ដឹងបរិហារដែលព្រះរាជអាជ្ញាទទួលដោយផ្ទាល់............... ១៧
ខ១ ពាក្យបណ្ដឹងទាមទារ.......................................................................................... ១៧
ខ២ ពាក្យបណ្ដឹងបរិហារ.......................................................................................... ១៨
គការបញ្ជូនពាក្យបណ្ដឹងដោយចៅក្រមស៊ើបសួរ........................................................... ១៨
ឃការបញ្ជូនពាក្យបណ្ដឹងដោយចៅក្រមជំនុំជម្រះ .......................................................... ១៨
ងពាក្យបណ្ដឹងដែលមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេ .ណី........................................ ១៩
**កថាខណ្ឌទី២ បញ្ជីរាយឈ្មោះសៀវភៅនៃសំណុំរឿងព្រហ្មទណ្ឌ**............................................ ២០
**ផ្នែកទី២ ជម្រើសនៃការចោទប្រកាន់**.................................................................................. ២១
**កថាខណ្ឌទី១ ការចោទប្រកាន់**........................................................................................ ២១
កការបើកការស៊ើបសួរ ............................................................................................ ២២
ក ១.ប្រភពដែលនាំឱ្យព្រះរាជអាជ្ញាអាចធ្វើសេចក្ដីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ.....២៣
ក១ ពាក្យបណ្ដឹង ឬពាក្យបរិហារទទួលដោយផ្ទាល់ ឬបញ្ជូនពីមន្.១.ត្រីនគរបាលយុត្តិធម៌.........................................................................................................២៣
ក២ ការជូនដំណឹងអំពីការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី.១. ............................ ២៤
ក៣ អធិបញ្ញារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌.១. .......................................................... ២៥
ក៤ ការធ្វើអធិបញ្ញារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍.១. .......................... ២៥
ក៥ ការស្នើសុំឱ្យបើកការស៊ើបសួរបន្ថែម.១. ............................................................. ២៦
ក៦ ការបញ្ជូនរឿងឱ្យបើកការស៊ើបសួរដោយចៅក្រមជំនុំជម្រះ.១. ......................... ២៦
ក២ ល័ក្ខខ័ណ្ឌចាំបាច់ដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ. ................. ២៦
ក៣ អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ. ............................................... ២៧
ខដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់. ...................................................................... ២៨
ខ១ លក្ខខណ្ឌទម្រង់. និងរយៈពេល........................................................................... ២៨
ខ២ មូលហេតុនៃការប្រើនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់. ........................................... ៣០
ខ១ បទលហុ.២........................................................................................................ ៣០
ខ២ បទមជ្ឈឹម.២. ....................................................................................................៣១
ខ៣ អានុភាពនៃដ.ីកាកោះហៅទៅជំនុំជម្រះផ្ទាល់ ........................................................៣១

គកំណត់ហេតុស្ដីពីនីតិវិធីបង្ហាញខ្លួនភ្លាម ........................................................................ ៣១
គ១. លក្ខខណ្ឌដើម្បីប្រើនីតិវិធីបង្ហាញខ្លួនភ្លាម .......................................................... ៣២
គ១ លក្ខខណ្ឌបទល្មើស.១. ........................................................................................ ៣២
គ ២.១.លក្ខខណ្ឌចំពោះការផ្តន្ទាទោស ........................................................................ ៣២
គ៣ លក្ខខណ្ឌអាយុ.១. ............................................................................................ ៣៣
គ៤ លក្ខខណ្ឌសំណុំរឿង.១. ......................................................................................... ៣៣
គ ២.នីតិវិធីនៃការបង្ហាញខ្លួនភ្លាម ................................................................................ ៣៤
គ៣ អានុភាពនៃកំណត់ហេតុបង្ហាញខ្លួនភ្លាម................................................................... ៣៥
គ១ ឱ្យតុលាការបើកសវនាការនៅថ្ងៃនោះតែម្តង.៣. .......................................................... ៣៥
គ២ ត្រូវតែចេញសាលក្រមនៅថ្ងៃនោះតែម្តង.៣. ............................................................... ៣៥
គ៣ អានុភាពឱ្យព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ.៣. ..................................................... ៣៥
គ៤ អានុភាពអាចឱ្យឃុំខ្លួនបណ្តោះអាសន្ន.៣. ................................................................... ៣៦
**កថាខណ្ឌទី២ការតម្កល់ទុករឿងឥតចាត់ការ** ...................................................................... ៣៦
កលក្ខខណ្ឌតម្កល់រឿងទុកឥតចាត់ការ ............................................................................. ៣៧
ខមូលហេតុតម្កល់រឿងទុកឥតចាត់ការ ............................................................................. ៣៧
ខ១ ខ្វះធាតុផ្សំបទល្មើស.១......................................................................................... ៣៧
ខ២ សំណុំរឿងរដ្ឋប្បវេណី.១. ...................................................................................... ៣៨
ខ.១៣ មូលហេតុមានចែងក្នុងច្បាប់. ................................................................................. ៣៨
ខ៤ មូលហេតុដទៃទៀត.១. ......................................................................................... ៤១
គនីតិវ .ិធីនៃការតម្កល់រឿងទុកឥតចាត់ការ .......................................................................... ៤២
ឃនីតិវិធី និងសេចក្តីសម្រេចនៃបណ្តឹងតវ៉ា . ......................................................................... ៤២
**សេចក្តីសន្និដ្ឋាន**.......................................................................................................... ៤៣
**អនុសាសន៍**................................................................................................................. ៤៤
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

នៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាមាត្រា១៣១ បានចែងថា "មានតែអង្គការអយ្យការទេដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា"។ មានន័យថាព្រះរាជអាជ្ញា គឺជាភាគីនៃបណ្តឹងក្នុងរឿងក្តីព្រហ្មទណ្ឌ មានតួនាទីតំណាងឱ្យរដ្ឋ តំណាងឱ្យសង្គម ការពារផលប្រយោជន៍ទូទៅ និងធ្វើបណ្តឹងអាជ្ញាចោទប្រកាន់ទៅតុលាការឱ្យផ្តន្ទាទោសចំពោះជនដែលប្រព្រឹត្តបទល្មើស។

នៅមុនពេលក្រមនីតិវិធីព្រហ្មទណ្ឌថ្មីឆ្នាំ២០០៧ប្រកាសឱ្យប្រើ តំណាងអយ្យការមានតែជម្រើសនៃការចោទប្រកាន់តែមួយគឺ ការចោទប្រកាន់បញ្ជូនរឿងឱ្យស៊ើបសួរតែមួយមុខប៉ុណ្ណោះ ហើយព្រះរាជអាជ្ញាត្រូវគោរពនូវគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ មានន័យថា នៅពេលណាមានបទល្មើសគឺព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់។ ត្បិតតែនីតិវិធីនេះ មានភាពល្អិតល្អន់បន្តិចក៏ដោយ ដែលទាមទារឱ្យតុលាការត្រូវតែធ្វើការស៊ើបអង្កេតបន្ថែម ដើម្បីត្រួតពិនិត្យលើយុត្តាធិការស៊ើបអង្កេតជៀសវាងកំហុសឆ្គងណាមួយដែលកើតក្នុងអំឡុងពេលស៊ើបអង្កេត និងបញ្ហាខ្វះចន្លោះនានាដែលជាកត្តានាំឱ្យបាត់ប្រយោជន៍ដល់ភាគីជនរងគ្រោះ និងភាគីជនជាប់ចោទ។ ប៉ុន្តែដោយសារតែនៅពេលដែលមានបទល្មើសកើតឡើង ព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់ និងការទាមទារឱ្យត្រូវតែបើកការស៊ើបសួរលើគ្រប់ករណី ដូច្នេះហើយទើបបណ្តាលឱ្យកើតមាននូវវិបត្តិមានចំនួន ដូចជាការចេញសេចក្តីសម្រេចរបស់តុលាការមានភាពយឺតយ៉ាវ ចំណាយថវិការដ្ឋច្រើនទៅលើការស៊ើបអង្កេតដដែលៗ មានការឃុំខ្លួនជនជាប់ចោទលើសពេលកំណត់ ហើយមានការកក់ស្ទះសំណុំរឿងជាច្រើន និងបញ្ហាផ្សេងទៀតជាអាទិ៍។

បញ្ហាទាំងអស់នេះហើយ បានជំរុញឱ្យនីតិករប្រមូលផ្តុំគ្នា ប្រជុំពិភាក្សាដើម្បីស្វែងរកវិធីដោះស្រាយចំពោះវិបត្តិដែលបានលើកឡើងខាងលើនេះ។ ជាលទ្ធផល តាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌដែលបានប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ យើងឃើញថា ពួកគេបានផ្តល់សេចក្តីទុកចិត្តទៅឱ្យចៅក្រមអយ្យការ ដោយប្រគល់នូវអំណាចឱ្យព្រះរាជអាជ្ញា អាចធ្វើការថ្លឹងថ្លែងអំពីចំណាត់ការរបស់ខ្លួនទៅលើសំណុំរឿងព្រហ្មទណ្ឌដែលខ្លួនកំពុងតែចាត់ការបាន ។

ប្រសិនបើពិនិត្យឱ្យកាន់តែស៊ីជម្រៅ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧នេះ បានផ្តល់ជម្រើសឱ្យព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬសម្រេចធ្វើបណ្តឹងសុំចោទប្រកាន់យុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះ ដើម្បីស្វែងរកឱ្យឃើញអំពីអត្ថិភាពនៃបទល្មើស ដើម្បីផ្តន្ទាទោសជនល្មើសតាមច្បាប់នេះបានស្តែងឱ្យឃើញថាក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧នេះ គោរពគោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ ដែលបើកសិទ្ធិឱ្យព្រះរាជអាជ្ញាមានសិទ្ធិថ្លឹងថ្លែងពីបទល្មើស និងការប៉ះពាល់ដល់សង្គម ថាតើគួរចោទប្រកាន់ ឬសម្រេចតម្កល់រឿងនោះទុកឥតចាត់ការ ដើម្បីឆ្លើយតប

ទៅនឹងវិបត្តិដែលជួបប្រទះខាងលើ។ ហើយការផ្តល់ជម្រើសឱ្យព្រះរាជអាជ្ញាអាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬអាចសម្រេចធ្វើការចោទប្រកាន់ គឺជាករណីថ្មីមួយរបស់ព្រះរាជអាជ្ញាតែជម្រើសនេះមានភាពស្មុគស្មាញជាងនីតិវិធីនៃច្បាប់ចាស់ ដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវតែយល់ច្បាស់អំពីនីតិវិធី និងលក្ខខណ្ឌចាំបាច់ទាំងឡាយដែលទាក់ទងនឹងការប្រើប្រាស់ជម្រើសនីមួយៗ។

ដូចបានរៀបរាប់ខាងលើ ការផ្តល់ជម្រើសឱ្យព្រះរាជអាជ្ញា គឺជាករណីដ៏ថ្មីមួយសម្រាប់ព្រះរាជអាជ្ញាដោយឆ្លងកាត់តាមការស្រាវជ្រាវផ្អែកតាមទ្រឹស្តីទាំងក្រមនីតិវិធីចាស់ និងក្រមនីតិវិធីថ្មីនេះ ខ្ញុំបាទ/នាងខ្ញុំយល់ឃើញថាមានករណីយយល់ខុសគ្នាច្រើនចំពោះការប្រើប្រាស់នីតិវិធីថ្មីនេះ។

គោលបំណងនៃការស្រាវជ្រាវ គឺចង់ធ្វើការវែកញែកនីតិវិធីថ្មីនេះឱ្យបានច្បាស់លាស់ជាងមុន ទើបខ្ញុំបាទ/នាងខ្ញុំ សម្រេចជ្រើសរើសយកប្រធានបទស្តីពី "ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌរបស់អង្គការអយ្យការ" មកធ្វើការសិក្សាស្រាវជ្រាវ ដោយផ្តោតសំខាន់តែទៅលើការតម្កល់រឿងទុកឥតចាត់ការ និងការសម្រេចចោទប្រកាន់តែប៉ុណ្ណោះ។ ខ្ញុំបាទ/នាងខ្ញុំនឹងព្យាយាមប្រមូលផ្តុំកម្រងឯកសារ និងពត៌មានផ្សេងៗដែលទាក់ទងនឹងប្រធានបទដាក់ចូលក្នុងសារណានេះ ដើម្បីក្លាយជាទន់បណ្តុះពុទ្ធិដល់អ្នកសិក្សាផ្នែកនីតិសាស្ត្រ។

ក្នុងការសិក្សាទៅលើប្រធានបទនេះ យើងខ្ញុំសូមធ្វើការសិក្សាទៅលើប្រវត្តិ និងគោលការណ៍សំខាន់ៗ រចនាសម្ព័ន្ធ និងផ្តោតសំខាន់ទៅចំណាត់ការសំណុំរឿងរបស់ចៅក្រមអយ្យការនៅក្នុងស្ថាប័នអយ្យការ។

តើប្រវត្តិរបស់ស្ថាប័នអយ្យការមានដំណើរការដូចម្តេចខ្លះ? តើស្ថាប័ននេះមានរចនាសម្ព័ន្ធយ៉ាងដូចម្តេច? តើជម្រើសចំពោះចំណាត់ការលើសំណុំរឿងព្រហ្មទណ្ឌរបស់ព្រះរាជអាជ្ញាមានអ្វីខ្លះ ហើយអានុភាពមានការខុសប្លែកគ្នាយ៉ាងដូចម្តេច នៅពេលព្រះរាជអាជ្ញាប្រើប្រាស់ជម្រើសនីមួយៗ?

ដើម្បីជាដំណោះស្រាយ ក៏ដូចជាការឆ្លើយតបទៅលើបញ្ហាគតិយុត្តិដូចដែលបានចោទឡើងខាងលើនេះ សារណានៃការសិក្សាស្រាវជ្រាវទៅលើប្រធានបទនេះ នឹងធ្វើការសិក្សាលម្អិតទៅលើប្រវត្តិ និងគោលការណ៍សំខាន់ៗនៃអង្គការអយ្យការ(ជំពូកទី១) រចនាសម្ព័ន្ធនៃអង្គការអយ្យការ(ជំពូកទី២) និងចំណាត់ការសំណុំរឿងរបស់អង្គការអយ្យការ(ជំពូកទី៣) នឹងត្រូវបានសិក្សាដូចតទៅ÷

# ជំពូកទី១ ប្រវត្តិ និងគោលការណ៍សំខាន់នៃអង្គការអយ្យការ

## ផ្នែកទី១ ប្រវត្តិស្ថាប័នអយ្យការនៅកម្ពុជា

រហូតមកទល់ពេលបច្ចុប្បន្ននេះ កម្ពុជាមិនមានឯកសារផ្លូវការណាមួយ ដែលអាចបញ្ជាក់អំពីប្រវត្តិនៃការកកើតតួនាទីរបស់បុគ្គលដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា នៅព្រះរាជាណាចក្រកម្ពុជានៅឡើយទេ។ តាមរយៈរឿងនិទាន និងឯកសារប្រវត្តិសាស្ត្រផ្សេងៗ យើងបានមើលឃើញថាអង្គព្រះមហាក្សត្រ គឺជាបុគ្គលដ៏សំខាន់ម្នាក់ដែលដឹកនាំដោយផ្ទាល់លើអំណាចទាំងបី។ មានន័យថាព្រះអង្គជាបុគ្គលតែអង្គឯង ដែលដោះស្រាយទាំងរឿងនយោបាយ សេដ្ឋកិច្ច និងនយោបាយព្រហ្មទណ្ឌរបស់នគរ។

យោងតាមអត្ថបទស្រាវជ្រាវរបស់លោកមេធាវី កុយ នាម បានពិពណ៌នាថា នៅពេលប្រជារាស្ត្រមានជម្លោះជាមួយគ្នា ពួកគេសុទ្ធតែយករឿងរបស់ខ្លួនទៅសុំឱ្យព្រះមហាក្សត្រកាត់សេចក្តី[១]ការលើកឡើងដូចនេះហាក់ដូចជាបានបង្ហាញថា មានតែព្រះមហាក្សត្រតែមួយអង្គប៉ុណ្ណោះ ដែលអាចធ្វើជាម្ចាស់បណ្តឹងចោទប្រកាន់ចំពោះសំណុំរឿងក្តីរបស់ប្រជារាស្ត្រ ហើយក៏ជាបុគ្គលដែលចេញសេចក្តីសម្រេចចំពោះបណ្តឹងទាំងអស់នោះផងដែរ។

ដើម្បីទទួលបានពត៌មានកាន់តែច្បាស់ អំពីការវិវឌ្ឍន៍នៃស្ថាប័នអយ្យការនៅព្រះរាជាណាចក្រកម្ពុជា ខ្ញុំបាទ/នាងខ្ញុំសូមធ្វើការបកស្រាយដោយធ្វើការបែងចែកអំពីស្ថាប័ននេះទៅតាមកាលបរិច្ឆេទនីមួយៗដូចទៅ ៖

### ក. ការបង្កើតស្ថាប័នអយ្យការអំឡុងឆ្នាំ១៩៣៧ មកទល់ឆ្នាំ១៩៧០

ក្រមពិភាក្សាព្រហ្មទណ្ឌ (បច្ចុប្បន្នហៅថាក្រមនីតិវិធីព្រហ្មទណ្ឌ) ឆ្នាំ១៩៣៧ បានឱ្យឈ្មោះស្ថាប័នដែលមានតួនាទីធ្វើបណ្តឹងអាជ្ញាថាជាអង្គការអយ្យការ។ ដោយធ្វើការបែងចែករចនាសម្ព័ន្ធអង្គការអយ្យការជាពីរថ្នាក់ គឺអង្គការអយ្យការអមសាលាដំបូង និងអង្គការអយ្យការអមសាលាជាន់ខ្ពស់។ ចំពោះបុគ្គលដែលធ្វើការងារជាតំណាងឱ្យអង្គការអយ្យការអមសាលាដំបូងមាន ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង ដោយឡែកបុគ្គលដែលជាតំណាងឱ្យអង្គការអយ្យការអមសាលាជាន់ខ្ពស់វិញ ត្រូវបានក្រមពិភាក្សាព្រហ្មទណ្ឌឱ្យឈ្មោះថា "ព្រះរាជបំរើ" និង"ភូឈួយព្រះរាជបំរើ"[២]។ អង្គការអយ្យការអមសាលាជាន់ខ្ពស់ ត្រូវបានបែងចែកជាពីរផងដែរ គឺអយ្យការអមសាលាឧទ្ធរណ៍ដែលមាន "ព្រះរាជបំរើ" ជាតំណាង និងអយ្យការអមសាលាវិនិច្ឆ័យាធិតី។

[១] មេធាវី កុយ នាម សៀវភៅស្តីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប ឆ្នាំ២០០៦ ទំព័រទី៣៩

[២] មេធាវី កុយ នាម សៀវភៅស្តីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប ឆ្នាំ២០០៦ ទំព័រទី៥៥

ក្រមពិភាក្សាព្រហ្មទណ្ឌឆ្នាំ១៩៣៧ មិនបានចែងអំពីនាមនៃបុគ្គលដែលតំណាងឱ្យអយ្យការអមសាលាវិនិច្ឆ័យាធិតីទេ រហូតមកដល់ថ្ងៃទី០៩ ខែមីនា ឆ្នាំ១៩៥៤ ទើបមានច្បាប់ស្តីពី "លក្ខន្តិកៈស្តីពីយុត្តាធិការចៅក្រម និងក្រឡាបញ្ជីខាងផ្នែកតុលាការ" បានកំណត់ពីឈ្មោះបុគ្គលដែលតំណាងឱ្យអយ្យការអមសាលាវិនិច្ឆ័យាធិតីថាជា អគ្គព្រះរាជអាជ្ញា[៣] ។

នាសម័យនេះតួនាទីព្រះរាជអាជ្ញានេះបានជំនួសឱ្យតួនាទីរបស់ចៅក្រមស៊ើបសួរ ឬតួនាទីរបស់សភាចារ្យបុរសដែលពីមុនមកពួកគេទាំងពីរនាក់នេះ ជាអ្នកបង្កសំណុំរឿងចោទប្រកាន់ទៅសាលាមជ្ឈឹម ឬទៅសាលាក្រុមចោទ[៤]។

## ខ. ស្ថាប័នអយ្យការអំឡុងឆ្នាំ១៩៧០ មកទល់ឆ្នាំ១៩៧៥

នៅក្នុងអំឡុងពេលនេះ យើងឃើញថាទោះបីជាបានផ្លាស់ប្តូរនូវរបប ពីរបបរាជានិយមមកជារបបសាធារណរដ្ឋនិយម ក៏យើងសង្កេតឃើញថាប្រព័ន្ធច្បាប់នៅកម្ពុជាក៏មិនបានផ្លាស់ប្តូរដែរ។ របបសាធារណរដ្ឋនិយម នៅតែបន្តនិរន្តរភាពនៃការអនុវត្តតាមប្រព័ន្ធតុលាការដែលបានបន្សល់ទុកកាលពីមុនដដែល ប៉ុន្តែគ្រាន់តែមានផ្លាស់ប្តូរលើការហៅឈ្មោះបន្តិចបន្តួច ដូចជាផ្លាស់ប្តូរពីព្រះរាជអាជ្ញាមកហៅថាជារដ្ឋអាជ្ញាវិញ។[៥]

## គ. ស្ថាប័នអយ្យការអំឡុងឆ្នាំ១៩៧៥ មកទល់ឆ្នាំ១៩៧៩

រាប់គិតចាប់ពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ មកទល់នឹងថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ កម្ពុជាបានសម្រេចជ្រើសរើសប្រកាន់យកនូវរបបមួយ គឺរបបកម្ពុជាប្រជាធិបតេយ្យ។ របបនេះមិនបានប្រកាសអោយនិរាករណ៍ទៅលើច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមុនក្តី ក៏យើងបានពិនិត្យឃើញថាកម្ពុជាមិនបានយកច្បាប់លិខិតបទដ្ឋានគតិយុត្ត និងប្រព័ន្ធនៃបែបផែនតុលាការណាមួយមកប្រើប្រាស់ឡើយ។ ដោយឡែកយើងសង្កេតឃើញថារបបនេះ បានបង្កើតនូវរដ្ឋធម្មនុញ្ញដែលចែងអំពីប្រព័ន្ធតុលាការថ្មីមួយដែលឱ្យឈ្មោះថាជា "តុលាការប្រជាជន" ហើយមានតែតុលាការតែមួយថ្នាក់ប៉ុណ្ណោះ។[៦]

ក្នុងន័យនេះយើងច្បាស់ជាយល់ថា ប្រជាជនគឺជាម្ចាស់បណ្តឹងអាជ្ញាហើយមានសិទ្ធិធ្វើបណ្តឹងទៅតុលាការនេះដើម្បីសុំឱ្យមានការជំនុំជម្រះក្តីឱ្យខ្លួនជាមិនខាន។ ដោយឡែកផ្ទុយទៅវិញតុលាការ

---

[៣] មេធាវី កុយ នាម សៀវភៅស្តីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប ឆ្នាំ២០០៦ ទំព័រទី៥៥

[៤] មេធាវី កុយ នាម សៀវភៅស្តីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប ឆ្នាំ២០០៦ ទំព័រទី៥៥

[៥] មេធាវី កុយ នាម សៀវភៅស្តីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប ឆ្នាំ២០០៦ ទំព័រទី៥៦

[៦] រដ្ឋធម្មនុញ្ញនៃកម្ពុជាប្រជាធិបតេយ្យបានប្រកាសឲ្យប្រើ ថ្ងៃទី៥ ខែមករា ឆ្នាំ១៩៧៦ ជំពូកទី៧ មាត្រា ៩

ប្រជាជននេះមិនបានដំណើរការឡើយ។ ជាក់ស្តែងគេសង្កេតឃើញថា គឺមានតែបុគ្គលដែលគេឱ្យឈ្មោះថាកម្មាភិបាលប៉ុណ្ណោះ ដែលជាអ្នកមានសមត្ថកិច្ចក្នុងការធ្វើបណ្តឹងចោទប្រកាន់ចំពោះបុគ្គលដែលបានប្រព្រឹត្តកំហុស ហើយដែលពេលនោះគេហៅអ្នកទាំងនោះថាជាអ្នកក្បត់។

**ឃ. ស្ថាប័នអយ្យការអំឡុងឆ្នាំ១៩៧៩ មកទល់ឆ្នាំ១៩៩២**

រយៈពេល៣ឆ្នាំ បន្ទាប់ពីរំដោះកម្ពុជាចាកចេញពីរបបកម្ពុជាប្រជាធិបតេយ្យ កម្ពុជាបានបង្កើតអង្គការអយ្យការឡើងវិញ។ ប៉ុន្តែនៅក្នុងតំណាក់កាលនោះ ទោះបីជាអង្គការនេះបានបង្កើតឡើងហើយក៏ដោយ ក៏ស្ថាប័ននេះហាក់ដូចជាគ្មានភាពរឹងមាំដូចកាលពីអតីតកាលឡើយ ព្រោះធនធានមនុស្សលើវិស័យយុត្តិធម៌នេះបានបាត់បង់ស្ទើរតែទាំងស្រុងទៅហើយ។ គឺនៅមុនឆ្នាំ១៩៧៥ កម្ពុជាមានរដ្ឋអាជ្ញាចំនួន៣៨នាក់ និងចៅក្រមមានចំនួន៩២នាក់។ ចំណែកឯនាពេលបង្កើតអង្គការអយ្យការឆ្នាំ១៩៨២វិញ គឺកម្ពុជានៅសល់តែរដ្ឋអាជ្ញាចំនួន៣នាក់តែប៉ុណ្ណោះ។ នាពេលនោះមានការជ្រើសរើសរដ្ឋអាជ្ញាបន្ថែម។ ហើយនីតិវិធីនៃការជ្រើសរើសរដ្ឋអាជ្ញានាពេលនោះ ធ្វើឡើងតាមរយៈគណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុង។ គណៈកម្មាធិការប្រជាជនបដិវត្តខេត្ត-ក្រុងត្រូវបញ្ជូនលទ្ធផលនៃការជ្រើសរើសទៅក្រសួងយុត្តិធម៌ដើម្បីផ្តល់យោបល់ និងសម្រេច។ បន្ទាប់ពីទទួលបានការយល់ព្រមពីក្រសួងយុត្តិធម៌ហើយ បេក្ខជនទាំងនោះត្រូវបានប្រកាសតែងតាំងដោយក្រុមប្រឹក្សារដ្ឋមន្ត្រី។ នៅក្នុងចំណាត់ការរឿងក្តីនាពេលនោះ អយ្យការមានតួនាទីស៊ើបអង្កេត ឬទទួលរបាយការណ៍ស៊ើបអង្កេតពីអង្គភាពស៊ើបអង្កេត។ បន្ទាប់ពីបានពិនិត្យ ឬបានបំពេញកិច្ចស៊ើបអង្កេតរួចហើយរដ្ឋអាជ្ញាធ្វើបណ្តឹងចោទប្រកាន់ទៅឱ្យតុលាការដើម្បីធ្វើការជំនុំជម្រះ។[៧]

នៅក្នុងឆ្នាំ១៩៨៥ រដ្ឋកម្ពុជាបានបង្កើតច្បាប់ស្តីពីការបង្កើតតុលាការប្រជាជនកំពូល និងមហាអយ្យការអមតុលាការកំពូលឡើង ហើយបញ្ញត្តិនេះបានប្រគល់តួនាទីឱ្យអគ្គរដ្ឋអាជ្ញា អគ្គរដ្ឋអាជ្ញារង និងរដ្ឋអាជ្ញាជាតំណាងឱ្យមហាអយ្យការអមតុលាការកំពូលនេះ។ ចំណែកឯនីតិវិធីនៃការជ្រើសរើសវិញ គឺអគ្គរដ្ឋអាជ្ញាត្រូវធ្វើការជ្រើសតាំងឡើងដោយរដ្ឋសភា តាមរយៈការបោះឆ្នោតសម្រាប់អណត្តិប្រាំឆ្នាំ។ អគ្គរដ្ឋអាជ្ញាដែលទទួលបានការតែងតាំង ហើយមានភារៈកិច្ចធ្វើការរៀបចំសមាសភាពអគ្គរដ្ឋអាជ្ញារង និងរដ្ឋអាជ្ញាដើម្បីសុំការយល់ព្រមពីក្រុមប្រឹក្សារដ្ឋ។[៨]

**ខ. ស្ថាប័នអយ្យការចាប់តាំងពីឆ្នាំ១៩៩២ មកទល់ឆ្នាំ២០០៧**

នៅថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ អាជ្ញាធរអន្តរកាលនៃអង្គការសហប្រជាជាតិបាន បង្កើតបទ

[៧] មេធាវី កុយ នាម សៀវភៅស្តីពីអយ្យការ ប្រវិត្ត និងការសិក្សាប្រៀបធៀប ឆ្នាំ២០០៦ ទំព័រទី៦០

[៨] មេធាវី កុយ នាម សៀវភៅស្តីពីអយ្យការ ប្រវិត្ត និងការសិក្សាប្រៀបធៀប ឆ្នាំ២០០៦ ទំព័រទី៦៤

បញ្ញត្តិថ្មីមួយស្តីពី "បទបញ្ញត្តិស្តីពី ប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាល"។ ហើយបទបញ្ញត្តិនេះ បានបញ្ញត្តិអំពីប្រព័ន្ធតុលាការថ្មីមួយដែលមានរចនាសម្ព័ន្ធនៃសាលាជម្រះក្តីបីថ្នាក់ គឺសាលាដំបូងនៅក្នុងតំបន់ ឬខេត្ត សាលាឧទ្ធរណ៍ និងតុលាការជាន់ខ្ពស់។ ហើយនៅតាមសាលាជម្រះក្តីនីមួយៗត្រូវតែមានស្ថាប័នអយ្យការនៅអមសាលាជម្រះក្តីនោះជានិច្ច។[៩]

អាជ្ញាធរអន្តរកាលនៃអង្គការសហប្រជាជាតិនោះ បានបង្កើតឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមនាពេលនោះផងដែរ។ មន្ត្រីតុលាការដែលបានបំរើការងារជាចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជីពីមុនមក ត្រូវបានអនុញ្ញាតឱ្យនៅបន្តបំពេញការងាររបស់ខ្លួនធម្មតា។

នៅក្នុងនីតិវីធីនៃប្រព័ន្ធច្បាប់ថ្មីនេះ បានបង្កើតឱ្យមានតួនាទីរបស់អយ្យការច្រើនជាងមុន។ ក្នុងអំឡុងឆ្នាំនោះ ដោយមើលឃើញថាសំណុំរឿងក្តីព្រហ្មទណ្ឌមានកំណើន ទើបនៅក្នុងឆ្នាំ១៩៩៤ ក្រសួងយុត្តិធម៌បានសម្រេចធ្វើការជ្រើសរើសព្រះរាជអាជ្ញាបន្ថែមទៀត។ ជាលទ្ធផលក្នុងការជ្រើសរើសវគ្គដំបូង ក្រសួងយុត្តិធម៌ជ្រើសរើសបានសិស្សចៅក្រម (សិស្សចៅក្រម និងសិស្សចៅក្រមអយ្យការ) ចំនួន៤២រូប។ ក្នុងមាត្រា២ បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌសម្រាប់អនុវត្តនៅប្រទេសកម្ពុជាក្នុងសម័យអន្តរកាលបានពន្យល់ថា សមាសភាពនៃក្រុមចៅក្រមមានទាំងចៅក្រម និងរដ្ឋអាជ្ញា។ ហើយនៅតាមសាលាជម្រះក្តីជាន់ដំបូងត្រូវមានរដ្ឋអាជ្ញាម្នាក់ [១០] ដែលបានប្រគល់ភារៈកិច្ចឱ្យធ្វើបណ្តឹងអាជ្ញាព្រហ្មទណ្ឌ ហើយគ្មានបុគ្គលផ្សេងទៀតអាចទទួលបានអំណាចឱ្យធ្វើបណ្តឹងអាជ្ញានេះជំនួសរដ្ឋអាជ្ញាឡើយ។

### ច. ស្ថាប័នអយ្យការចាប់តាំងពីឆ្នាំ២០០៧ មកទល់បច្ចុប្បន្ន

នៅអំឡុងឆ្នាំ២០០៧ រហូតមកដល់ពេលបច្ចុប្បន្ន (ខែកញ្ញា ឆ្នាំ២០១៤) កម្ពុជាបានបង្កើតបានបទបញ្ញត្តិចំនួនពីរដែលចែងអំពីតួនាទី អំពីមុខងារ និងសិទ្ធិអំណាចរបស់ស្ថាប័នអយ្យការនេះ។ គឺនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ព្រះបាទនរោត្តម សីហមុនីបានឡាយព្រះហស្តលេខាប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌនៅថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា។

---

[៩] បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ មាត្រា២ មាត្រា៣ មាត្រា៤ មាត្រា៥

[១០] បទបញ្ញត្តិស្តីពីប្រព័ន្ធតុលាការ ច្បាប់ព្រហ្មទណ្ឌ និង នីតិវិធីព្រហ្មទណ្ឌ សម្រាប់អនុវត្តនៅប្រទេសកម្ពុជា ក្នុងសម័យអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២ មាត្រា ៣

បទបញ្ញត្តិទាំងពីរនេះមានលក្ខណៈច្បាស់លាស់ជាងមុខ ដែលធានាឱ្យការអនុវត្តការងាររបស់ចៅក្រមអយ្យការ ហើយឆ្លើយតបចំពោះការវិវឌ្ឍន៍ទៅនឹងស្ថានភាពបច្ចុប្បន្នរបស់កម្ពុជា។

ក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនេះបានចាត់ថ្នាក់អង្គការអយ្យការជាបីថ្នាក់គឺ៖[១១]

- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា អមតុលាការកំពូល។
- អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា អមសាលាឧទ្ធរណ៍។
- ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញា អមសាលាដំបូង។

ហើយយោងតាមច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាបានកំណត់ឋានន្តរស័ក្តិនៃក្រមខណ្ឌអយ្យការជាបីថ្នាក់ផងដែរគឺ៖

- ឧត្តមព្រះរាជអាជ្ញា
- វិរៈព្រះរាជអាជ្ញា
- អនុព្រះរាជអាជ្ញា

រាល់ការតំឡើងឋានន្តរស័ក្តិ ឬការផ្លាស់ប្តូរមុខងារផ្សេងៗរបស់ចៅក្រមអយ្យការ ត្រូវធ្វើឡើងទៅតាមនីតិវិធី ដែលមានកំណត់នៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញានេះ។ នៅក្នុងបទបញ្ញត្តិថ្មីនេះ បានផ្តល់សិទ្ធិអំណាចមួយចំនួនធំ ទៅឱ្យរដ្ឋមន្ត្រីក្រសួងយុត្តិធម៌លើកិច្ចការគ្រប់គ្រងដឹកនាំអង្គការអយ្យការ។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវបានប្រគល់មុខងារជានាឋានានុក្រមនៃអង្គការអយ្យការ អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខអក្សរទៅអង្គការគ្រប់ជាន់ថ្នាក់។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានអគ្គនាយកដ្ឋានកិច្ចការអយ្យការ និងព្រហ្មទណ្ឌនៃក្រសួងយុត្តិធម៌ជាសេនាធិការដើម្បីជាជំនួយដល់កិច្ចដំណើរការគ្រប់គ្រងអង្គការនេះ។[១២]

## ផ្នែកទី ២ គោលការណ៍សំខាន់ៗនៃស្ថាប័ន និងចៅក្រមអយ្យការ

### កថាខណ្ឌទី១. គោលការណ៍សំខាន់ៗនៃស្ថាប័នអយ្យការ

#### ក. គោលការណ៍ឯកភាព ឬឋានានុក្រម

យោងតាមក្រមពិភាក្សាព្រហ្មទណ្ឌឆ្នាំ១៩៦២ បានបញ្ញត្តិថាស្ថាប័នអយ្យការ គឺជា "ក្រុមអយ្យការ"។ បន្ថែមពីលើនេះទៀតកថាខណ្ឌទី១ មាត្រា៧៥ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញាបានបញ្ញត្តិបន្ថែមទៀតថា អង្គអយ្យការជាអង្គឯកភាពដែលព្រះរាជអាជ្ញាទាំងអស់ត្រូវស្ថិតនៅក្រោមការដឹកនាំ និងត្រួតពិនិត្យតាមឋានានុក្រម។ បញ្ញាត្តិទាំងពីរនេះបានបង្ហាញឱ្យឃើញថា

[១១] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ មាត្រា៧៨

[១២] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ មាត្រា៧៥

ស្ថាប័នអយ្យការនេះ ជាអង្គភាពដែលមានឯកភាពជាមួយគ្នា ក្នុងការបំពេញការងារតំណាងឱ្យតែស្ថាប័នខ្លួន និងទទួលខុសត្រូវរួមគ្នា។ ចៅក្រមអយ្យការទាំងអស់ ត្រូវបំពេញការងារស្ថិតក្រោមការដឹកនាំទៅតាមឋានានុក្រមរបស់ខ្លួន។ ដោយឡែកឋានានុក្រមនោះ ត្រូវបែងចែកតាមថ្នាក់នៃសាលាជម្រះក្តីនីមួយៗមានដូចជា៖ នៅអយ្យការអមសាលាដំបូង មានព្រះរាជអាជ្ញាអមសាលាដំបូងជានាយឋានានុក្រម នៅមហាអយ្យការអមសាលាឧទ្ធរណ៍មានអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ជានាយឋានានុក្រម និងនៅមហាអយ្យការអមតុលាការកំពូល មានអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលជានាយឋានានុក្រម។[១៣]

នៅក្នុងទំនាក់ទំនងនៃការងាររបស់ខ្លួន ចៅក្រមអយ្យការត្រូវគោរពជាចំបាច់នូវគោលការណ៍ឋានានុក្រម មានន័យថានៅសាលាដំបូងគ្រប់ព្រះរាជអាជ្ញារងទាំងអស់ ត្រូវស្ថិតនៅក្រោមការដឹកនាំនិងការត្រួតពិនិត្យពីព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូង។ រីឯនៅសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញានិងអគ្គព្រះរាជអាជ្ញារងត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យដោយអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍។ ចំណែកឯនៅតុលាការកំពូល ព្រះរាជអាជ្ញារង និងអគ្គព្រះរាជអាជ្ញារងនៃតុលាការកំពូល ត្រូវស្ថិតនៅក្រោមការដឹកនាំ និងការត្រួតពិនិត្យដោយអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមតុលាការកំពូល ។

ក្រៅពីនេះនៅក្នុងក្របខ័ណ្ឌនៃដំណើរការរឿងក្តីព្រហ្មទណ្ឌ ចៅក្រមអយ្យការទាំងអស់ត្រូវតែគោរពទៅតាមអធិបញ្ជានៃឋានានុក្រមរបស់ខ្លួន។ បានសេចក្តីថាព្រះរាជអាជ្ញារងត្រូវគោរពតាមអធិបញ្ជាពីព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងដែលខ្លួនស្ថិតនៅ។ រីឯព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងវិញត្រូវគោរពតាមអធិបញ្ជារបស់ អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍ ឬអធិបញ្ជារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ នៅក្នុងចំណាត់ការសំណុំរឿងក្តីនេះដែររដ្ឋមន្ត្រីក្រសួងយុត្តិធម៌ក៏អាចធ្វើអធិបញ្ជាទៅឱ្យព្រះរាជអាជ្ញាអមសាលាដំបូង ឬអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អំពីបទល្មើសដែលខ្លួនបានដឹង។ ចំពោះការធ្វើអធិបញ្ជានេះអាចធ្វើការណែនាំជាលាយលក្ខណ៍អក្សរដែលត្រូវបានដាក់បញ្ចូលក្នុងសំណុំរឿងឱ្យធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការគួរ[១៤]។ ប៉ុន្តែទោះបីជាគ្រប់ចៅក្រមអយ្យការទាំងអស់ ត្រូវតែគោរពតាមអធិបញ្ជារបស់ថ្នាក់លើរបស់ខ្លួនក៏ដោយក៏នៅក្នុងពេលសវនាការ ចៅក្រមអយ្យការអាចធ្វើការកត់សម្គាល់ដោយផ្ទាល់មាត់ដោយសេរីតាមការ

[១៣] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ មាត្រា៧៥

[១៤] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា២៩

ដែលខ្លួនយល់ឃើញថាស្របតាមសតិសម្បជញ្ញៈរបស់ខ្លួន[15] ហើយការកត់សម្គាល់នេះ មិនត្រូវបាន ចាត់ទុកជាការរំលោភបំពាននូវគោលការណ៍ឋានានុក្រម ដែលជាមូលហេតុនាំឱ្យមានការចោទប្រកាន់ ខាងវិន័យណាមួយឡើយដោយសារតែការបញ្ចេញការយល់ឃើញរបស់ខ្លួន នៅក្នុងពេលសវនាការ នោះទេ។ បញ្ញត្តិនៃមាត្រា៣០នៃក្រមនីតិវិធីព្រហ្មទណ្ឌនេះក៏មានសុភាសិតច្បាប់របស់បារាំងមួយដែល បកប្រែជាភាសាខ្មែរថា "បកាជាទាសី សម្តីដោយសេរី" ហើយសុភាសិតនេះ ត្រូវបានកម្ពុជាទទួល យកមកធ្វើជាមូលដ្ឋានដើម្បីរៀបចំច្បាប់របស់ខ្លួនតាំងពីអតីតកាលរហូតមកទល់បច្ចុប្បន្ន ។

**ខ. គោលការណ៍ឯករាជ្យ**

គោលការណ៍ឯករាជ្យភាពរបស់អង្គភាពអយ្យការ គឺជាគោលការណ៍ដែលបញ្ជាក់ថាអង្គការ អយ្យការមានឯករាជ្យភាពរបស់ខ្លួន ហើយដែលមិនស្ថិតនៅក្រោមអំណាចនៃសាលាជម្រះក្តីដែលខ្លួន អមនោះឡើយ។ នៅសាលាជម្រះទាំងឡាយគ្មានអំណាចត្រួតពិនិត្យកិច្ចការរបស់ព្រះរាជអាជ្ញាឡើយ បើទោះជាក្នុងករណី ដែលព្រះរាជអាជ្ញាមានកំហុសឆ្គងយ៉ាងណាក៏ដោយក៏សាលាជម្រះក្តីនោះមិន ត្រូវចុះក្នុងសេចក្តីសម្រេចរបស់ខ្លួនយកការស្តីបន្ទោសអ្វីចំពោះព្រះរាជអាជ្ញាឡើយ។ ចំពោះបម្រាម នេះត្រូវអនុវត្តទាំងក្នុងរឿងព្រហ្មទណ្ឌ និងរឿងក្តីផ្សេងទៀត។ ប៉ុន្តែសាលាជម្រះក្តីនោះ អាចលើក សំណើរទៅនាយកឋានានុក្រមរបស់ព្រះរាជអាជ្ញាអំពីកំហុសឆ្គងរបស់ព្រះរាជអាជ្ញានោះបាន។[16]

**កថាខណ្ឌទី២ គោលការណ៍សំខាន់ៗនៃចៅក្រមអយ្យការ**

**ក. គោលការណ៍មិនប្តឹងជំទាស់ចិត្ត**

ទោះបីជាព្រះរាជអាជ្ញាត្រូវបានចាត់ទុកថាជាចៅក្រមក៏ដោយ ក៏គេមិនអាចប្តឹងជំទាស់ចិត្តចៅក្រម អយ្យការបានដែរ។ ចៅក្រមអយ្យការធ្វើការងារតំណាងឱ្យស្ថាប័នរបស់ខ្លួនដើម្បីការពារផលប្រយោជន៍ សាធារណៈ និងប្រយោជន៍ទូទៅរបស់សង្គម។ ចៅក្រមអយ្យការអាចតំណាងឱ្យគ្នាទៅវិញទៅមក បាននៅគ្រប់កិច្ចនីតិវិធីទាំងអស់ ដូច្នេះសេចក្តីសម្រេចរបស់ចៅក្រមអយ្យការត្រូវបានចាត់ទុកជាសេចក្តី សម្រេចរបស់អង្គអយ្យការទាំងមូលផងដែរ ។

ម្យ៉ាងទៀតតំណាងអយ្យការមានឋានៈត្រឹមតែជាភាគីនៃរឿងក្តីប៉ុណ្ណោះ ដូច្នេះសេចក្តីសម្រេច របស់ចៅក្រមអយ្យការគ្រាន់តែជាការប្តឹងសុំឱ្យតុលាការអនុវត្តន៍ច្បាប់តែប៉ុណ្ណោះ គ្មានអានុភាពជា ការសម្រេចសេចក្តីអំពីទោសឡើយ។[17]

[15] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៣០

[16] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ មាត្រា៧៥

[17] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៥៥៦

**ខ. គោលការណ៍អវិភាគកម្ម**

គោលការណ៍អវិភាគ សំដៅដល់ការបំពេញការងាររបស់សមាជិកម្នាក់ៗ នៃអង្គអយ្យការតំណាងឱ្យអង្គភាពរួម ឬដើម្បីប្រយោជន៍សមូហភាព ក្នុងគោលដៅធ្វើឱ្យសង្គមមានសណ្ដាប់ធ្នាប់ និងសុវត្ថិភាព។ យោងតាមគោលការណ៍នេះ ទើបបានជានៅចំពោះមុខសាលាជម្រះក្ដីទាំងអស់ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងតែងតែប្រើប្រាស់ពាក្យថា "យើងជាតំណាងអយ្យការ" ធ្វើសេចក្ដីសន្និដ្ឋានតាំងនាមឱ្យអង្គអយ្យការ។[១៨]

ចំណែកឯមាត្រា៧៥ កថាខណ្ឌទី២ នៃច្បាប់ស្ដីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា បានបញ្ញត្តិថាអង្គការអយ្យការគឺជាអង្គអវិភាគ ដែលតម្រូវឱ្យព្រះរាជអាជ្ញាដែលបំពេញមុខងារនៅអយ្យការអមសាលាជម្រះក្ដីនីមួយៗ មានកាតព្វកិច្ចរួមគ្នាក្នុងមុខងារហើយអាចជំនួសគ្នាទៅវិញទៅមកបាន។

តាមគោលការណ៍នេះ តំណាងអយ្យការច្រើនរូបអាចបន្តការងារពីគ្នាបាននៅក្នុងសំណុំរឿងតែមួយតាមរយៈការចាត់តាំងរបស់នាយឋានានុក្រមរបស់ខ្លួនបាន។

**គ. គោលការណ៍មិនទទួលខុសត្រូវ**

ចៅក្រមអយ្យការបំពេញការងារជាសមូហភាព ធ្វើសេចក្ដីសន្និដ្ឋានសម្រេចចិត្តតំណាងឱ្យអង្គអយ្យការរបស់ខ្លួនទាំងមូលមិនមែនក្នុងនាមបុគ្គលណាមួយឡើយ ហេតុដូច្នេះបានជាចៅក្រមអយ្យការមិនត្រូវបានដាក់ឱ្យទទួលខុសត្រូវ ចំពោះការធ្វើសេចក្ដីសម្រេចចិត្តរបស់ខ្លួនណាមួយឡើយ។

ម្យ៉ាងទៀតនៅក្នុងចំណាត់ការសំណុំរឿងក្ដី ក៏មិនបានមើលឃើញថាព្រះរាជអាជ្ញាមានសិទ្ធិអំណាចពាក់ព័ន្ធនឹងការសម្រេចចិត្តផងដែរ ព្រោះថាចៅក្រមអយ្យការមានតួនាទីត្រឹមតែជាភាគីនៃរឿងក្ដីដែលមានសិទ្ធិត្រឹមតែស្នើសុំឱ្យតុលាការអនុវត្តច្បាប់តែប៉ុណ្ណោះ។

## ជំពូកទី២ រចនាសម្ព័ន្ធ និងឋានានុក្រមនៃអង្គការអយ្យការ

### ផ្នែកទី១ ឋានានុក្រមនៃអង្គការអយ្យការ

**ក រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

រដ្ឋមន្ត្រីក្រសួងយុត្តិធមិ៍ គឺជានាយឋានានុក្រមនៃអង្គអយ្យការទាំងមូល។ រដ្ឋមន្ត្រីក្រសួងយុត្តិធមិ៍អាចធ្វើអន្តាគមន៍ទៅលើអង្គការអយ្យការទាំងមូល នៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាទាំងផ្នែករដ្ឋបាល និងការធ្វើចំណាត់ការសំណុំរឿង។ ចំពោះការអន្តាគម៍ផ្នែករដ្ឋបាល គឺរដ្ឋមន្ត្រីក្រសួងយុត្តិធមិ៍លើកសំណើរធ្វើការតែងតាំង ធ្វើការផ្អាក់ពីមុខងារ ដាក់ឱ្យនៅក្រៅក្របខណ្ឌ ធ្វើការផ្លាស់ប្ដូរ ដាក់ឱ្យនៅទំនេរ និងលុបឈ្មោះព្រះរាជអាជ្ញាទាំងអស់ទៅឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

[១៨] មេធាវី កុយ នាម សៀវភៅស្ដីពីអយ្យការ ប្រវត្តិ និងការសិក្សាប្រៀបធៀប ឆ្នាំ ២០០៦ ទំព័រទី៧៤

បន្ទាប់ពីនេះ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ ដើម្បីតែងតាំង ផ្លាច់ពីមុខងារ ដាក់ឱ្យនៅក្រៅក្របខណ្ឌ ធ្វើការផ្លាស់ប្តូរ ឬដាក់ឱ្យនៅភាពទំនេរ និងលុបឈ្មោះព្រះរាជអាជ្ញាទាំងអស់បាន។[១៩]

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចចេញលិខិតបទដ្ឋានគតិយុត្ត និងសេចក្តីណែនាំចាំបាច់នានាដើម្បីធានាដំណើរការនៃការប្រព្រឹត្តទៅល្អប្រសើរនៃការគ្រប់គ្រងរដ្ឋបាល និងអាចចាត់ឱ្យធ្វើអធិការកិច្ចទៅលើបញ្ហាណាមួយជាកំណត់នៅគ្រប់សាលាជម្រះក្តីគ្រប់ជាន់ថ្នាក់។[២០]

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអមសាលាដំបូងត្រូវរៀបចំ និងធ្វើរបាយការណ៍អំពីបទល្មើស និងសកម្មភាពការងារជូនមករដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[២១]

ចំណែកឯការអន្តាគមន៍ផ្នែកសំណុំរឿងវិញ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយហានានុក្រមនៃអង្គការអយ្យការទាំងមូល អាចធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅឱ្យអគ្គព្រះរាជអាជ្ញា និងព្រះរាជអាជ្ញាគ្រប់ជាន់ថ្នាក់ ឱ្យធ្វើការចោទប្រកាន់ ឬធ្វើសេចក្តីសន្និដ្ឋានយ៉ាងណាតាមការដែលរដ្ឋមន្ត្រីយល់ឃើញថាជាការគួរ ហើយគ្រប់អធិបញ្ញារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវតែដាក់បញ្ចូលក្នុងសំណុំរឿង។

ត្បិតតែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើអធិបញ្ញាមែន ប៉ុន្តែរដ្ឋមន្ត្រីក្រសួងយុត្តិធម៌មិនអាចធ្វើអធិបញ្ញាដល់អគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាឱ្យធ្វើការតម្កល់រឿងទុកឥតចាត់ការ នូវសំណុំរឿងព្រហ្មទណ្ឌណាមួយឡើយ។[២២]

ក្នុងករណីដែលកើតមានបទល្មើសធ្ងន់ធ្ងរ ព្រះរាជអាជ្ញាត្រូវរាយការណ៍ជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ឱ្យបានដឹង ហើយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ត្រូវរាយការណ៍បន្តជូនរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឱ្យបានដឹង។[២៣]

---

[១៩] ច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ មាត្រា៨៩

[២០] ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ មាត្រា១១

[២១] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៦ មាត្រា៧៦

[២២] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា២៩

[២៣] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤០

**ខ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ គឺជានាយឋានានុក្រមនៃអង្គការអយ្យការដែលស្ថិតក្រោមសម្ថកិច្ចដែនដីរបស់ខ្លួន។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើអន្តាគមន៍ទៅលើអង្គការអយ្យការទាំងទៅលើផ្នែករដ្ឋបាល និងផ្នែកសំណុំរឿង។

ចំពោះការអន្តាគមន៍ផ្នែករដ្ឋបាល អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចធ្វើអធិការកិច្ចនៅគ្រប់អង្គការអយ្យការទាំងឡាយដែលស្ថិតនៅក្រោមដែនដីរបស់ខ្លួន។[២៤]

ព្រះរាជអាជ្ញាត្រូវរាយការណ៍អំពីកំហុសទាំងឡាយ ដែលប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ក្នុងពេលអនុវត្តការងាររបស់ខ្លួន ទៅឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឱ្យបានដឹងដើម្បីឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិដើម្បីផ្តើមដំណើរការនៃនីតិវិធីដាក់វិន័យ។[២៥]

ចំណែកឯការអន្តាគមន៍ផ្នែកសំណុំរឿងវិញ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចទទួលបណ្តឹងតវ៉ាចំពោះដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ។ បន្ទាប់មកអគ្គព្រះរាជអាជ្ញាអាចពិនិត្យពាក្យបណ្តឹងតវ៉ានោះ និងសំណុំរឿងដែលព្រះរាជអាជ្ញាបញ្ជូនមកខ្លួន។ ប្រសិនបើពិនិត្យទៅឃើញថាការតវ៉ានោះមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជាអាជ្ញាអមសាលាឧទ្ធរណ៍ចេញអធិបញ្ជាដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់បាន ប៉ុន្តែបើពិនិត្យឃើញថាការតម្កល់រឿងទុកឥតចាត់ការរបស់ព្រះរាជអាជ្ញាមានមូលហេតុត្រឹមត្រឹមនោះ អគ្គព្រះរាជអាជ្ញាសាលាឧទ្ធរណ៍សម្រេចតម្កល់សេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការនោះទុកជាបានការ។[២៦]

**ផ្នែកទី២ រចនាសម្ព័ន្ធនៃអង្គការអយ្យការ**

តួនាទីរបស់អយ្យការក្នុងក្របខ័ណ្ឌនៃដំណើរការរឿងក្តីព្រហ្មទណ្ឌ គឺជាភាគីនៅក្នុងរឿងក្តីជាបុគ្គលដែលតំណាងឱ្យសង្គមធ្វើបណ្តឹងសុំទៅយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះឱ្យផ្តន្ទាទោសជនស្មើសតាមច្បាប់។

អង្គការអយ្យការមិនចូលរួមនៅក្នុងការសម្រេចសេចក្តីទេ ប៉ុន្តែមានកាតព្វកិច្ចឃ្លាំមើល និងជម្រុញឱ្យការសម្រេចសេចក្តីរបស់តុលាការមានភាពច្បាស់លាស់ត្រឹមត្រូវ និងយុត្តិធម៌ក្លាយជាប្រយោជន៍ដល់សង្គម។ មាត្រា២៧នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា អយ្យការធ្វើការចោទប្រកាន់ខាង

---

[២៤] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៣៨

[២៥] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៦៤

[២៦] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤១

ព្រហ្មទណ្ឌ និងសន្និដ្ឋានឱ្យមានការអនុវត្តច្បាប់។ អយ្យការធានារ៉ាប់រងការអនុវត្តសេចក្តីសម្រេចខាងផ្នែកព្រហ្មទណ្ឌនឹងយកចិត្តទុកដាក់លើការផ្សព្វផ្សាយដីកាបង្គាប់ឱ្យចាប់ខ្លួន។ ក្នុងនាមជាភាគីក្នុងរឿងក្តីអយ្យការត្រូវមានតំណាងរបស់ខ្លួននៅគ្រប់យុត្តាធិការជម្រះក្តីទាំងអស់។

ស្ថាប័នអយ្យការមានរចនាសម្ព័ន្ធចាត់តាំងដូចខាងក្រោម៖

- មហាអយ្យការអមតុលាការកំពូល
- មហាអយ្យការអមសាលាឧទ្ធរណ៍
- អយ្យការអមសាលាដំបូងរាជធានី ខេត្ត

**ក. អយ្យការអមសាលាដំបូងរាជធានី ខេត្ត**

នៅតាមអយ្យការអមសាលាដំបូងរាជធានី ខេត្ត មានព្រះរាជអាជ្ញាមួយរូប និងព្រះរាជអាជ្ញារងច្រើនរូបទៀត ដែលដើរតួនាទីជាតំណាងឱ្យស្ថាប័នអយ្យការធ្វើបណ្តឹងអាជ្ញាចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ និងសុំឱ្យអនុវត្តន៍ច្បាប់នៅចំពោះមុខយុត្តាធិការស៊ើបសួរ ឬយុត្តធិការជំនុំជម្រះ។

ព្រះរាជអាជ្ញា ដឹកនាំសម្របសម្រួលការងាររបស់ព្រះរាជអាជ្ញារងទាំងអស់ ដែលនៅក្រោមឋានានុក្រមរបស់ខ្លួន ហើយប្រគល់អំណាចទាំងអស់របស់ខ្លួនឱ្យព្រះរាជអាជ្ញារងទាំងនោះ ក្នុងការត្រួតពិនិត្យបទល្មើស ស្រាវជ្រាវបទល្មើស និងធ្វើការចោទប្រកាន់បទល្មើស។ យោងតាមច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាបានកំណត់ក្របខណ្ឌរបស់ចៅក្រមអយ្យការជា៣(បី) ឋានន្តរស័ក្តិគឺ៖

- ឧត្តមព្រះរាជអាជ្ញា
- វរៈព្រះរាជអាជ្ញា
- អនុព្រះរាជអាជ្ញា

ជារៀងរាល់ឆ្នាំនៅសប្តាហ៍ទី១នៃខែមករា ព្រះរាជអាជ្ញាអមសាលាដំបូង មានភារៈកិច្ចធ្វើការវាយតម្លៃ និងដាក់ពន្ទុឱ្យព្រះរាជអាជ្ញាដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់ខ្លួន។ ការតម្លើងថ្នាក់ និងការតម្លើងប្រាក់បៀវត្សជូនព្រះរាជអាជ្ញារងត្រូវផ្អែកតាមពិន្ទុ និងយោបល់របស់ព្រះរាជអាជ្ញាដែលជានាយឋានានុក្រមរបស់ខ្លួននោះ។

**ខ.មហាអយ្យការអមសាលាឧទ្ធរណ៍**

យោងតាមមាត្រា៩០ នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី១៦ ខែ កក្កដា ឆ្នាំ២០១៤ បានបញ្ញាត្តិថាសាលាឧទ្ធរណ៍ជាសាលាជម្រះក្តីថ្នាក់ទីពីរ។ ហើយសាលាឧទ្ធរណ៍ត្រូវបានបង្កើតលើសពីចំនួន១ (មួយ) គឺមានសាលាឧទ្ធរណ៍នៅភ្នំពេញ និងសាលាឧទ្ធរណ៍តំបន់។

នៅសាលាឧទ្ធរណ៍នីមួយៗមានមហាអយ្យការនៅអមជានិច្ច។ អង្គការអយ្យការនេះត្រូវបានឱ្យឈ្មោះថាមហាអយ្យការអមសាលាឧទ្ធរណ៍ដែលមានអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាតំណាងឱ្យអង្គការអយ្យការអមតុលាការនេះ។

ក្នុងនាមជាតំណាងឱ្យមហាអយ្យការអមសាលាឧទ្ធរណ៍ អគ្គព្រះរាជអាជ្ញា មានតួនាទីឃ្លាំមើល និងធ្វើការត្រួតពិនិត្យនគរបាលយុត្តិធម៌។ មានអំណាចអាចកោះអញ្ជើញអ្នកទទួលខុសត្រូវនៃអង្គភាពនគរបាលទាំងនេះ។ អគ្គព្រះរាជអាជ្ញាអាចធ្វើអធិការកិច្ច និងមានអំណាចអាចធ្វើអធិបញ្ជាទៅដល់អង្គការនគរបាលទាំងនេះបាន។

មិនតែប៉ុណ្ណោះ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក៏មានតួនាទីចូលរួមក្នុងការសុំឱ្យមានការគោរពច្បាប់នៅពេលមានបណ្ដឹងឧទ្ធរណ៍ និងបណ្ដឹងតវ៉ាផ្សេងៗទៀតដែលដាក់ជូនខ្លួនពិនិត្យផងដែរ។

**គ.មហាអយ្យការអមតុលាការកំពូល**

មហាអយ្យការអមតុលាការកំពូលមានតែមួយគត់ ដែលមានទីតាំងនៅរាជធានីភ្នំពេញ។ អង្គការនេះត្រូវបានតំណាងដោយអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាការកំពូលក្រោមការដឹកនាំ និងទទួលខុសត្រូវរួមដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល។

អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានតួនាទីចូលរួមក្នុងការសុំឱ្យមានការគោរពច្បាប់នៅពេលមានបណ្ដឹងសាទុក្ខ បណ្ដឹងសើរើ និងបណ្ដឹងតវ៉ាផ្សេងៗទៀតដែលដាក់ជូនតុលាការកំពូលពិនិត្យ។

## ជំពូកទី៣ ចំណាត់ការលើសំណុំរឿងរបស់អយ្យការ

### ផ្នែកទី១ បណ្ដឹងព្រហ្មទណ្ឌ និងបញ្ជីឈ្មោះសៀវភៅនៃសំណុំរឿងព្រហ្មទណ្ឌ

បណ្ដឹងអាជ្ញា និងបណ្ដឹងរដ្ឋប្បវេណីជាបណ្ដឹងពីរផ្សេងគ្នា។ បណ្ដឹងអាជ្ញាមានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្ដន្ទាទោសជនដែលប្រព្រឹត្តនោះតាមច្បាប់កំណត់។ រីឯបណ្ដឹងរដ្ឋប្បវេណីវិញ មានគោលបំណងតែធ្វើឱ្យមានការជួសជុលការខូចខាត និងជម្ងឺចិត្ត ដែលបណ្ដាលមកពីបទល្មើសដល់ជនរងគ្រោះតែប៉ុណ្ណោះ[២៧]។ បណ្ដឹងទាំងពីរនេះត្រូវផ្ដើមឡើងដោយបុគ្គលពីរផ្សេងគ្នា គឺនៅពេលមានបទល្មើសកើតឡើង តំណាងអយ្យការមានភារៈកិច្ចចម្បងធ្វើបណ្ដឹងអាជ្ញា។ រីឯជនរងគ្រោះ ឬសិទ្ធិវន្តរបស់គេ ឬបុគ្គលផ្សេងទៀតដែលច្បាប់ទទួលស្គាល់មានសិទ្ធិតាមច្បាប់ធ្វើបណ្ដឹងរដ្ឋប្បវេណី។ ក៏ប៉ុន្តែជនរងគ្រោះ ឬមេធាវីរបស់ខ្លួនក៏អាចធ្វើឱ្យ បណ្ដឹងព្រហ្មទណ្ឌមានចលនាតាមរយៈការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីបានដែរ។[២៨]

[២៧] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា២

[២៨] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១៣៨

ព្រះរាជអាជ្ញាដែលតំណាងឱ្យស្ថាប័នអយ្យការទាំងមូល ដែលក្នុងនាមផលប្រយោជន៍ទូទៅ នៅពេលបានដឹងអំពីបទល្មើស ឬបានទទួលសំណុំរឿងនីតិវិធីដែលបញ្ជូនមកពីមន្ត្រីនគរបាល ឬដោយមធ្យោបាយផ្សេងទៀតមានភារៈកិច្ចតាំងខ្លួនជាភាគីនៃបណ្តឹង។ ហើយថ្លឹងថ្លែងអំពីចំណាត់របស់ខ្លួនក្នុងការធ្វើបណ្តឹងអាជ្ញា ឬធ្វើការតម្កល់រឿងទុកឥតចាត់ការ។ ក្នុងករណីតំណាងអយ្យការយល់ថាអំពើនោះជាបទល្មើសព្រហ្មទណ្ឌ តំណាងអយ្យការមានជម្រើសជាច្រើនដើម្បីធ្វើបណ្តឹងអាជ្ញា។ ការជ្រើសរើសជម្រើសណាមួយអាស្រ័យទៅលើស្ថានភាពនៃសំណុំរឿង និងនីតិវិធីដែលច្បាប់តម្រូវឱ្យធ្វើ។ តំណាងអយ្យការត្រូវតែប្តឹងសុំទៅយុត្តាធិការស៊ើបសួរ ឱ្យបើកការស៊ើបសួរចំពោះបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមដែលស្មុគស្មាញ ឬអាចប្តឹងសុំឱ្យធ្វើការជំនុំជម្រះតែម្តងចំពោះបទលហុ ឬបទមជ្ឈិមតូចតាចមួយចំនួន ដែលបានបំពេញល័ក្ខខ័ណ្ឌដែលកំណត់ដោយច្បាប់ ឬធ្វើការជំនុំជម្រះចំពោះបទមជ្ឈិមតូចតាច។

**កថាខណ្ឌទី១ នីតិវិធីទទួលបណ្តឹងព្រហ្មទណ្ឌ**

ព្រះរាជអាជ្ញា មានតួនាទីរក្សាសណ្តាប់ធ្នាប់សាធារណៈមានភារៈកិច្ចឃ្លាំមើលការអនុវត្តច្បាប់ និងប្តឹងចោទប្រកាន់គ្រប់បុគ្គលដែលបង្កឱ្យមានអសន្តិសុខសង្គមទៅសាលាជម្រះក្តី។ តំណាងអយ្យការត្រូវបានមាត្រា១៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាផ្តល់អំណាចឱ្យធ្វើជាម្ចាស់បណ្តឹងអាជ្ញាអាចធ្វើបណ្តឹងចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ នៅពេលដែលខ្លួនបានដឹងអំពីការកើតឡើងនៃបទល្មើស។ តំណាងអយ្យការអាចទទួលដំណឹងអំពីបទល្មើសតាមមធ្យោបាយផ្សេងៗហើយថ្លឹងថ្លែងអំពីអត្ថិភាពនៃបទល្មើសចំពោះរឿងហេតុដែលខ្លួនបានដឹង នៅមុនពេលចាប់ផ្តើមធ្វើបណ្តឹងចោទប្រកាន់ចំពោះអំពើល្មើសទាំងនោះទៅយុត្តាធិការស៊ើបសួរ ឬទៅយុត្តាធិការជំនុំជម្រះក្នុងគោលបំណងដើម្បីស្វែងរកការពិត ហើយផ្តន្ទាទោសជនដែលខ្លួនបានសង្ស័យថាបានប្រព្រឹត្តបទល្មើសតាមច្បាប់។

តើតំណាងអយ្យការអាចតាំងខ្លួនជាម្ចាស់បណ្តឹងព្រហ្មទណ្ឌតាមមធ្យោបាយណាខ្លះ?

**ក.ពាក្យបណ្តឹងទាមទារ និងពាក្យបណ្តឹងបរិហារដែលមន្ត្រីនគរបាលយុត្តិធម៌បញ្ជូនមក**

**ក.១ ពាក្យបណ្តឹងទាមទារ**

ជនរងគ្រោះ ឬសិទ្ធិវ័ន្តនៃជនរងគ្រោះ ឬអង្គការសមាគមន៍ដែលច្បាប់ទទួលស្គាល់ហើយបានប្រកាសដោយត្រឹមត្រូវយ៉ាងតិចបំផុត៣(បី)ឆ្នាំ នៅមុនកាលបរិច្ឆេទនៃការកើតបទល្មើសអាចដាក់ពាក្យបណ្តឹងទាមទារ ក្នុងឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី ចូលមកមន្ត្រីនគរបាលយុត្តិធម៌ដែលមានសមត្ថកិច្ចត្រួតពិនិត្យអត្ថិភាពនៃបទល្មើស។ ពាក្យបណ្តឹងទាមទារ ត្រូវមានបញ្ជាក់អំពីអង្គហេតុ និងកម្មវត្ថុនៃការទាមទារឱ្យបានច្បាស់លាស់។

បណ្តឹងទាមទារដែលធ្វើឡើងដោយបុគ្គលជាដើមបណ្តឹងរដ្ឋប្បវេណីនេះ គឺជាបណ្តឹងសាមញ្ញប៉ុណ្ណោះ គ្មានអានុភាពនាំឱ្យមានការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌឡើយ។[២៩] មន្ត្រីនគរបាលយុត្តិធម៌ដែលទទួលបានពាក្យបណ្តឹងទាមទារ ត្រូវតែធ្វើកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនេះ។ បន្ទាប់ពីធ្វើកំណត់ហេតុបណ្តឹង មន្ត្រីនគរបាលយុត្តិធម៌ ចាប់ផ្តើមធ្វើការស៊ើបអង្កេតបឋមដោយឯកឯង ឬសុំការអនុញ្ញាតពីព្រះរាជអាជ្ញាដើម្បីបើកការស៊ើបអង្កេតបឋម។ ក្នុងករណីខ្លះ មន្ត្រីនគរបាលយុត្តិធម៌មិនបើកការស៊ើបអង្កេតដោយខ្លួនឯងទេ។

មន្ត្រីនគរបាលយុត្តិធម៌ តែត្រូវបញ្ជូនកំណត់ហេតុស្តីពីការដាក់ពាក្យបណ្តឹងនោះ ទៅឱ្យព្រះរាជអាជ្ញាដើម្បីចាត់ការបន្ត។ ក្នុងករណីមន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកចាត់ការពាក្យបណ្តឹងបានពិនិត្យឃើញថា អង្គហេតុដែលគេប្តឹងនោះ ជាបទល្មើសព្រហ្មទណ្ឌមន្ត្រីនគរបាលយុត្តិធម៌ត្រូវ តែកសាងសំណុំរឿងហើយបញ្ជូនមកអយ្យការអមសាលាដំបូង នាទីកន្លែងដែលមន្ត្រីនគរបាលយុត្តិធម៌នោះស្ថិតនៅ មន្ត្រីនគរបាលយុត្តិធម៌មិនអាចតម្កល់រឿងព្រហ្មទណ្ឌទុកឥតចាត់ការបានទេ ទោះបីជាមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះក្តី[៣០]។

**ក.២ ពាក្យបណ្តឹងបរិហារ**

ដើម្បីចូលរួមបង្ក្រាបបទល្មើស ដែលតែងបង្កឱ្យមានអសន្តិសុខដល់សណ្តាប់ធ្នាប់សាធារណៈ សាធារណៈជន ឬអាជ្ញាធរសាធារណៈ ឬមន្ត្រីរាជការគ្រប់រូបនៅពេលបានដឹងអំពីបទល្មើសឧក្រិដ្ឋឬបទមជ្ឈិមត្រូវតែ ជូនដំណឹងទៅឱ្យអាជ្ញាធរមានសមត្ថកិច្ច(មន្ត្រីនគរបាលយុត្តិធម៌)បានដឹងអំពីរឿងហេតុដែលជាបទល្មើសនោះ។ ការជូនដំណឹងអំពីបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមនេះត្រូវបានច្បាប់ឱ្យឈ្មោះថាជាពាក្យបរិហារ។ មាត្រា៤២នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិ ថាជាកាតព្វកិច្ចថាអាជ្ញាធរសាធារណៈ ឬមន្ត្រីរាជការគ្រប់រូបត្រូវតែជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌។ អ្នកប្តឹងត្រូវផ្តល់ព័ត៌មានអំពីរឿងហេតុដែលខ្លួនបានដឹង ឬត្រូវនាំយកមកជាមួយនូវសម្ភារៈដែលជនល្មើសប្រើប្រាស់ដើម្បីប្រព្រឹត្តបទល្មើស ឬឯកសារដែលពាក់ព័ន្ធផ្សេងៗទៀតដែលមានទាក់ទងទៅនឹងការប្រព្រឹត្តបទល្មើសដល់មន្ត្រីនគរបាលយុត្តិធម៌។

មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលដំណឹងអំពីប្តឹងបរិហារ ត្រូវធ្វើកំណត់ហេតុបណ្តឹងហើយត្រូវបើកការស៊ើបអង្កេតបឋមដើម្បីកំណត់អំពីអត្តសញ្ញាណជនល្មើស ឬធ្វើការផ្ទៀងផ្ទាត់សេចក្តីរាយការណ៍ដែលធ្វើឡើងជាបណ្តឹងបរិហារនោះ ការបើកការស៊ើបអង្កេតនេះ គឺជាការផ្ទៀងផ្ទាត់ជំហាន

---

[២៩] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៦

[៣០] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៧៥

ដំបូងទៅលើករណីនៃការរាយការណ៍នេះ។ ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌បានពិនិត្យឃើញថាពិតជាមានអត្ថិភាពនៃបទល្មើសដូចការរាយការណ៍ពិតប្រាកដមែន មន្ត្រីនគរបាលយុត្តិធម៌បើកការស៊ើបអង្កេត និងប្រមូលភស្តុតាងហើយរៀបចំជាសំណុំរឿងបញ្ជូនមកព្រះរាជអាជ្ញាដើម្បីចាត់ការបន្ត។

**ខ. ពាក្យបណ្តឹង និងពាក្យបណ្តឹងបរិហារដែលព្រះរាជអាជ្ញាទទួលដោយផ្ទាល់**

**ខ.១ ពាក្យបណ្តឹងទាមទារ**

បុគ្គលគ្រប់រូបដែលប្រកាសថាខ្លួនជាអ្នករងគ្រោះនៃបទល្មើស ឬសិទ្ធិវន្តនៃជនរងគ្រោះ ឬអង្គការសមាគមន៍ ដែលច្បាប់ទទួលស្គាល់ហើយបានប្រកាសដោយត្រឹមត្រូវ យ៉ាងតិចបំផុត៣(បី)ឆ្នាំនៅមុនពេលកើតបទល្មើស អាចដាក់ពាក្យបណ្តឹងទាមទារក្នុងឋានៈជាភាគីដើមបណ្តឹងរដ្ឋប្បវេណីចូលមកព្រះរាជអាជ្ញាដោយផ្ទាល់បាន។ ពាក្យបណ្តឹងទាមទារដែលព្រះរាជអាជ្ញាទទួលបានពីបុគ្គលខាងលើនោះគ្រាន់តែ ជាបណ្តឹងទាមទារឱ្យសងការខូចខាតផ្នែករដ្ឋប្បវេណីដែលកើតចេញពីព្យសនកម្មនៃបទល្មើសព្រហ្មទណ្ឌតែប៉ុណ្ណោះ។ ពាក្យបណ្តឹងទាមទារ គឺគ្រាន់តែជាពាក្យបណ្តឹងសាមញ្ញគ្មានអានុភាពនាំឱ្យព្រះរាជអាជ្ញាធ្វើការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌឡើយ[៣១]។

បន្ទាប់ពីទទួលបានពាក្យបណ្តឹងទាមទារ ព្រះរាជអាជ្ញាអាចធ្វើការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម។ បន្ទាប់ពីកិច្ចស៊ើបអង្កេត ឬការស្រាវជ្រាវបានបញ្ចប់ចប់សព្វគ្រប់ ព្រះរាជអាជ្ញាថ្លឹងថ្លែងអំពីចំណាត់ការរបស់ខ្លួនចំពោះការប្តឹងទាមទារនោះ។ ក្នុងករណីព្រះរាជអាជ្ញាយល់ឃើញថាបណ្តឹងទាមទារមានមូលហេតុត្រឹមត្រូវ ហើយមានតម្រុយដែលបង្ហាញឱ្យឃើញថាអំពើនោះជាបទល្មើសព្រហ្មទណ្ឌនោះព្រះរាជាអាជ្ញាត្រូវធ្វើការចោទប្រកាន់ ហើយបញ្ជូនសំណុំរឿងទៅឱ្យយុត្តាធិការស៊ើបសួរ ឬទៅឱ្យយុត្តាធិការជំនុំជម្រះ ដើម្បីស្វែងរកការពិត និងផ្តន្ទាទោសជនល្មើសតាមច្បាប់។

ផ្ទុយទៅវិញនៅក្នុងករណីដែលពាក្យបណ្តឹងទាមទារស្ថិតនៅដោយគ្មានចម្លើយ ឬពាក្យបណ្តឹងដែលទទួលបាននោះត្រូវបានតម្កល់ទុកឥតចាត់ការដោយព្រះរាជអាជ្ញា នោះជនរងគ្រោះនៃបទល្មើស ឬសិទ្ធិវន្តនៃជនរងគ្រោះ ឬបុគ្គលពាក់ព័ន្ធដទៃទៀតអាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ឱ្យចេញអធិបញ្ជាដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់បាន[៣២]។

[៣១] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៦

[៣២] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៦

**ខ.២ ពាក្យបណ្តឹងបរិហារ**

ព្រះរាជអាជ្ញា អាចតាំងខ្លួនជាម្ចាស់បណ្តឹងព្រហ្មទណ្ឌ នៅពេលទទួលបានពាក្យបរិហារពីសាធារណៈជន ពីអាជ្ញាធរសាធារណៈ ឬមន្ត្រីគ្រប់រូបដែលបានដឹងអំពីការកើតឡើងនូវបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមបន្ទាប់ពីបើកការស៊ើបអង្កេតបឋមរួចរាល់ហើយ។

យោងតាមមាត្រា៤២ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិជាកាតព្វកិច្ចថាអាជ្ញាធរដែលខ្លួនកំពុងបំពេញមុខងារបានដឹងអំពីការកើតឡើងបទឧក្រិដ្ឋ ឬបទមជ្ឈិម។ ពាក្យប្តឹងបរិហារនេះគ្រាន់តែជាពាក្យប្តឹងសាមញ្ញប៉ុណ្ណោះមិនមានអានុភាព បង្ខំឱ្យព្រះរាជអាជ្ញាត្រូវតែធ្វើការចោទប្រកាន់ជាបទព្រហ្មទណ្ឌឡើយ។

ឧទាហរណ៍៖ ព្រះរាជអាជ្ញាបានទទួលសេចក្តីរាយការណ៍ពីអ្នកកាសែត ដែលរាយការណ៍ថាមានការលួចដឹងជញ្ជូនឈើក្រញូងខុសច្បាប់ដោយមានមធ្យោបាយជារថយន្តជាអាទិ៍។

**គ.ការបញ្ជូនពាក្យបណ្តឹងដោយចៅក្រមស៊ើបសួរ**

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៧ កំណត់យ៉ាងជាក់លាក់ថានៅក្នុងករណីមានបណ្តឹងសាមញ្ញចៅក្រមស៊ើបសួរត្រូវតែបញ្ជូនបណ្តឹងនោះទៅព្រះរាជអាជ្ញា។[៣៣]

ក្នុងស្ថានភាពបែបនេះ គឺក្រមនីតិវិធីព្រហ្មទណ្ឌកំពុងតែគោរពតាមរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ដែលបានកំណត់ថាមានតែអង្គការអយ្យការប៉ុណ្ណោះ គឺជាម្ចាស់បណ្តឹងអាជ្ញា។[៣៤]

**ឃ. ការបញ្ជូនពាក្យបណ្តឹងដោយចៅក្រមជំនុំជម្រះ**

ចំពោះវិធីមួយទៀតដែលបើកសិទ្ធិអោយមានការបញ្ជូនពាក្យបណ្តឹងទៅព្រះរាជអាជ្ញានោះគឺក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ មាត្រា៣៤៨ បានកំណត់ថាតុលាការអាចធ្វើការសម្រេចសេចក្តីបានតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូនដីកាបញ្ជូន ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុនៃការបង្ហាញខ្លួនភ្លាម។

ក្នុងករណីដែលតុលាការសម្រេចរួមជាក្រុមហើយយល់ឃើញថា អង្គហេតុដែលត្រូវបានប្តឹងនោះបង្កើតជាបទមជ្ឈឹម ឬបទលហុ តុលាការនោះនៅតែមានសមត្ថកិច្ចដើម្បីជម្រះសេចក្តីដដែល។

ប៉ុន្តែនៅក្នុងកថាខណ្ឌទី៣ មាត្រាដដែលបានកំណត់ថាក្នុងករណីដែលតុលាការសម្រេចដោយចៅក្រមតែម្នាក់គត់ហើយយល់ឃើញថាអង្គហេតុដែលត្រូវបានប្តឹងនោះ បង្កើតជាបទឧក្រិដ្ឋតុលាការនោះបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញាវិញដើម្បីបើកការស៊ើបសួរ។[៣៥]

---

[៣៣] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១២៤

[៣៤] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ មាត្រា១៣១

[៣៥] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ៣៤៨

## ខ. ពាក្យបណ្តឹងដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

នីតិវិធីនៃការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរនេះ គឺជានីតិវិធីថ្មីដែលបង្កើតឡើងតាមរយៈក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។ នីតិវិធីនេះ បើកសិទ្ធិឱ្យតែជនរងគ្រោះ ឬមេធាវីតំណាងឱ្យជនរងគ្រោះនៃបទល្មើសឧក្រិដ្ឋ ឬបទមជ្ឈិមតែប៉ុណ្ណោះ ទើបអាចដាក់ពាក្យបណ្តឹងតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះយុត្តាធិការស៊ើបសួរបាន[៣៦]។

នៅពេលទទួលបានពាក្យបណ្តឹង តាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះចៅក្រមស៊ើបសួរ ធ្វើការកត់សំគាល់នូវការដាក់ពាក្យបណ្តឹងនេះដោយដីកាហើយជូនដំណឹងទៅព្រះរាជអាជ្ញាដើម្បីឱ្យបើកការចោទប្រកាន់ តាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ បន្ទាប់ពីពិនិត្យពាក្យបណ្តឹងដែលបញ្ជូនមកឱ្យខ្លួនហើយ ប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា អំពើនោះមិនមែនជាបទល្មើសព្រហ្មទណ្ឌទេ ឬប្រសិនបើបណ្តឹងអាជ្ញាត្រូវបានផុតរលត់ដោយយោងតាមមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជអាជ្ញាអាចសុំដល់ចៅក្រមស៊ើបសួរកុំឱ្យបើកការស៊ើបសួរបាន។ កិច្ចស្នើសុំកុំឱ្យបើកការស៊ើបសួររបស់ព្រះរាជអាជ្ញានេះ មិនមែនជាកាតព្វកិច្ចដែលចៅក្រមស៊ើបសួរត្រូវតែគោរពតាមនោះទេ។ ក្នុងករណីដែលចៅក្រមស៊ើបសួរ នៅតែសម្រេចបើកការស៊ើបសួរ ចៅក្រមស៊ើបសួររូបនោះ ត្រូវចេញដីកាសម្រេចដោយមានសំអាងហេតុ ហើយជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញាអំពីកិច្ចនៃការផ្តើមបើកការស៊ើបសួររបស់ខ្លួន[៣៧]។ បទបញ្ញត្តិនៃមាត្រា១៣៨ និងមាត្រា១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌមិនបញ្ញត្តិឱ្យច្បាស់ថាតើកិច្ចស៊ើបសួររបស់ចៅក្រមស៊ើបសួរចំពោះករណីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចាំបាច់ឱ្យត្រូវតែមានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរពីព្រះរាជអាជ្ញានោះទេ។ ហេតុដូចនេះហើយទើបមានការបកស្រាយឡើងថាទោះ បីជាព្រះរាជអាជ្ញាមិនយល់ព្រមធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរក៏ដោយ ក៏ចៅក្រមស៊ើបសួរនៅតែមានអំណាចបើកការស៊ើបសួរដោយឯកឯងបានដែរ។ ព្រោះចៅក្រមស៊ើបសួរអាចសំអាងលើកហាខណ្ឌទី៥ នៃមាត្រា១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលបញ្ញត្តិថាចៅក្រមស៊ើបសួរគ្រាន់តែចេញដីកាសម្រេចស៊ើបសួរ ហើយជូនដំណឹងអំពីដីកាសម្រេចនេះទៅឱ្យព្រះរាជអាជ្ញាតែប៉ុណ្ណោះ។

នីតិវិធីនៃការបើកការស៊ើបសួរតាមរយៈការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរនេះត្រូវបានមតិមួយចំនួនលើកឡើងថា បានចែងផ្ទុយទៅនឹងគោលបំណងនៃមាត្រា១៣១ ថ្មីនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាដែលចែងថា "មានតែអង្គការអយ្យការទេដែលមាន

---

[៣៦] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១៣៨

[៣៧] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១៣៩

សិទ្ធិធ្វើបណ្តឹងអាជ្ញា" ដូចនេះមានន័យថា ខ្លឹមសារកឋាខណ្ឌទី៥នៃមាត្រា១៣៩នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះអធម្មនុញ្ញភាព។ ជាអាទិ៍យើងបានមើលឃើញថា សូម្បីតែមាត្រាមួយចំនួននៃក្រមនីតិវិធីព្រហ្មទណ្ឌខ្លួនឯង ក៏បានចែងបដិប្បញ្ញត្តិទៅនឹងបទបញ្ញត្តិនៃមាត្រា១៣៨ និងមាត្រា១៣៩ស្តីពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនោះផងដែរ។ ដូចជានៅក្នុងកឋាខណ្ឌទី១ នៃមាត្រា១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិថា "ការស៊ើបសួរត្រូវបានបើកដោយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញា" ហើយបញ្ញត្តិនៃកឋាខណ្ឌទី៣នៃមាត្រាដដែលនោះ បានបំពេញបន្ថែមថា "ចៅក្រមស៊ើបសួរមិនអាចបំពេញកិច្ចស៊ើបសួរណាមួយបាន ដោយគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់ព្រះរាជអាជ្ញាបានទេ"។

**កថាខណ្ឌទី២ បញ្ជីរាយឈ្មោះសៀវភៅនៃសំណុំរឿងព្រហ្មទណ្ឌ**

នៅក្នុងចំណាត់ការលើរឿងក្តីព្រហ្មទណ្ឌ នៅអយ្យការអមសាលាដំបូងរាជធានី-ខេត្តមានដាក់ឱ្យដំណើការសៀវភៅមួយចំនួន ដូចមានរាយឈ្មោះខាងក្រោមនេះ៖

-សៀវភៅចុះបណ្តឹងសំណុំរឿងព្រហ្មទណ្ឌ

-សៀវភៅចុះបណ្តឹងអនុវត្ត

-សៀវភៅពិសេស

-សៀវភៅពិសេសកិច្ចការអនុវត្ត

-សៀវភៅចុះលេខលិខិត ចេញ ចូល

-សៀវភៅតាមដានការអនុវត្តទោសរបស់ទណ្ឌិត

-សៀវភៅទទួលយកវត្ថុតាង និងការបញ្ជាឱ្យចូលខ្លួន

-សៀវភៅចុះលេខដីកាកោះសវនាការ

-សៀវភៅតាមដានការឃាត់ខ្លួន

-សៀវភៅចាត់តាំងតំណាងអយ្យការ

-សៀវភៅដោះលែងទណ្ឌិត

-សៀវភៅចុះលេខឃុំខ្លួន មិនឃុំខ្លួន អនុញ្ញាតឱ្យនៅក្រៅឃុំ មិននៅក្រៅឃុំ លើកលែងចោទប្រកាន់

-សៀវភៅបញ្ជូនឯកសារ

-សៀវភៅសុំប្តឹងតវ៉ា

-សៀវភៅបញ្ជូនសំណុំរឿង

-សៀវភៅដាក់គុកបង្ខំរូបរាងកាយ

## ផ្នែកទី២ ជម្រើសនៃការចោទប្រកាន់

ព្រះរាជអាជ្ញាមានសិទ្ធិជាគោលការណ៍ក្នុងការផ្ដើមធ្វើបណ្ដឹងអាជ្ញា ចាប់តាំងពីពេលដែលខ្លួនបានដឹងអំពីបទល្មើស។ ជាអាទិ៍ព្រះរាជអាជ្ញាប្រើប្រាស់គោលការណ៍កាលានុវត្តភាពនៅក្នុងជម្រើសនៃការចោទប្រកាន់របស់ខ្លួន។ គោលការណ៍កាលានុវត្តភាពនេះផ្ដល់ឱ្យព្រះរាជអាជ្ញានូវសេរីភាពក្នុងការវាយតម្លៃថាគួរតែធ្វើបណ្ដឹងអាជ្ញា ឬតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកទៅលើស្ថានទម្ងន់ទោសនៃបទល្មើស កាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ភាពរឹករវដល់សណ្ដាប់ធ្នាប់សាធារណៈ និងភស្តុតាងផ្សេងៗទៀតដែលប្រមូលបានក្នុងពេលស៊ើបអង្កេត។

គោលការណ៍នេះអនុញ្ញាតឱ្យព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការ ហើយទោះបីជាច្បាប់បានចែងទុកថាអំពើនោះ គឺជាបទល្មើសដែលត្រូវតែផ្ដន្ទាទោសក៏ដោយ។ អាចនិយាយបានម្យ៉ាងទៀតថាគោលការណ៍កាលានុវត្តភាពរបស់ព្រះរាជអាជ្ញា បានបំពានទៅលើបទបញ្ញត្តិស្ដីពីគោលការណ៍នីត្យានុកូលភាពនៃមាត្រា៣នៃក្រមព្រហ្មទណ្ឌចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ដែលចែងឱ្យប្រកាសអំពីទោសចំពោះអំពើដែលច្បាប់ចាត់ទុកថាជាបទល្មើស។

### កថាខណ្ឌទី១ ការចោទប្រកាន់

មាត្រា១៣១ថ្មីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថាមានតែអង្គការអយ្យការតែមួយគត់ដែលមានសិទ្ធិធ្វើបណ្ដឹងអាជ្ញា។ បណ្ដឹងអាជ្ញាមានគោលបំណងឱ្យពិនិត្យអត្ថិភាពនៃបទល្មើសបង្ហាញឱ្យឃើញអំពីពិរុទ្ធភាពចំពោះជនល្មើស និងផ្ដន្ទាទោសជនល្មើសតាមច្បាប់។ ក្នុងនាមជាបុគ្គលដែលតំណាងឱ្យផលប្រយោជន៍ទូទៅ ជាអ្នកធានារក្សាឱ្យបាននូវសណ្ដាប់ធ្នាប់សាធារណៈ និងជាបុគ្គលតំណាងឱ្យស្ថាប័នអយ្យការទាំងមូល ក្នុងការឃ្លាំមើលការអនុវត្តច្បាប់នៅក្នុងសង្គមទើបតំណាងអយ្យការ ត្រូវបានផ្ដល់ឱ្យនូវបុព្វសិទ្ធិអាចធ្វើបុរេវិនិច្ឆ័យដោយសន្មត់ទុកជាមុនថាជនទាំងឡាយដែលខ្លួនសង្ស័យថាបានប្រព្រឹត្តបទល្មើសពិតជាបានប្រព្រឹត្តបទល្មើស។ ហើយប្ដឹងសុំទៅយុត្តាធិការស៊ើបសួរ ឬយុត្តាធិការជំនុំជម្រះធ្វើការស្រាវជ្រាវ និងផ្ដន្ទាទោសជននោះតាមច្បាប់[៣៨]។

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានផ្ដល់មធ្យោបាយបីដល់តំណាងអយ្យការនៅក្នុងនីតិវិធីនៃការប្ដឹងសុំឱ្យមានការផ្ដន្ទាទោសជនល្មើស។ តំណាងអយ្យការថ្លឹងថ្លែងអំពីជម្រើសរបស់ខ្លួន ដោយពិចារណាទៅលើល័ក្ខខ័ណ្ឌចាំបាច់នៃកិច្ចនីតិវិធីដែលត្រូវធ្វើអាស្រ័យទៅតាមប្រភេទនៃបទល្មើស និងអាស្រ័យទៅតាមស្ថានភាពជាក់ស្ដែងនៃបទល្មើសជាអាទិ៍។

---

[៣៨] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៥

**ក. ការបើកការស៊ើបសួរ**

តំណាងអយ្យការ អាចប្ដឹងសុំទៅយុត្តាធិការស៊ើបសួរឱ្យធ្វើការស្រាវជ្រាវចំពោះអំពើដែលខ្លួនសង្ស័យថាគឺជាបទល្មើសតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះ គឺជានីតិវិធីមួយដែលតំណាងអយ្យការអាចធ្វើដើម្បីបើកការស៊ើបសួរប្រឆាំងទៅលើបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះ ឬប្រឆាំងទៅលើអញ្ញាតជន[៣៩]។

ចៅក្រមស៊ើបសួរ ដែលទទួលបណ្ដឹងអំពីអង្គហេតុដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការនេះ អាចធ្វើការស៊ើបសួរតែចំពោះអង្គហេតុដែលបញ្ជូនមកឱ្យខ្លួនពិនិត្យតែប៉ុណ្ណោះ។ នៅពេលបំពេញកិច្ចស៊ើបសួរប្រសិនជាមានលេចចេញនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុថ្មីនោះ ទៅតំណាងអយ្យការដើម្បីឱ្យតំណាងអយ្យការអាចប្ដឹងសុំឱ្យចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនោះតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីណាមួយឡើយ បើមិនអាចទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមពីតំណាងអយ្យការនោះទេ[៤០]។

ក្នុងករណីនេះ មានចំណោទគតិយុត្តមួយបានចោទឡើងថា៖ ស្ថិតនៅក្នុងពេលកំពុងស៊ើបសួរហើយមានលេចចេញអង្គហេតុថ្មី ដែលចៅក្រមស៊ើបសួរយល់ឃើញថាជាបទល្មើសព្រហ្មទណ្ឌតែបែរជាតំណាងអយ្យការមិនព្រមប្ដឹងសុំចោទប្រកាន់ឱ្យស៊ើបសួរបន្ថែមទេដោយ ទោះបីជាចៅក្រមស៊ើបសួរបានជូនដំណឹងអំពីការលេចចេញនូវអង្គហេតុថ្មីរួចហើយក៏ដោយ។ ចំពោះករណីនេះតើចៅក្រមស៊ើបសួរអាចធ្វើការស៊ើបសួរបន្ថែមទៅលើអង្គហេតុថ្មី ដោយគ្រាន់តែយោងតាមបទបញ្ញត្តិនៃមាត្រា ១៣៨ និងមាត្រា១៣៩នៃក្រមនីតិវិធីព្រហ្មទណ្ឌស្ដីពីការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីនៅចំពោះមុខចៅក្រមស៊ើបសួរបានដែរឬទេ?

ចម្លើយគឺឆ្លើយថាបានដោយគ្រាន់តែមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី នៅចំពោះមុខចៅក្រមស៊ើបសួរ ដោយធ្វើសេចក្ដីបញ្ជាក់ពីការលេចចេញនូវអង្គហេតុថ្មីដែលជាបទល្មើសព្រហ្មទណ្ឌនោះតែប៉ុណ្ណោះ។

---

[៣៩] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៤ កថាខណ្ឌទី២

[៤០] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១២៥

ចៅក្រមស៊ើបសួរ មិនចាំបាច់មានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម ពីតំណាងអយ្យការឡើយប្រសិនបើអង្គហេតុថ្មីនោះ គ្រាន់តែជាស្ថានទម្ងន់ទោសទៅលើអង្គហេតុដែលព្រះរាជអាជ្ញាបានរៀបរាប់នៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរដំបូងប៉ុណ្ណោះ[៤១]។

គ្រប់បុគ្គលដែលត្រូវបានតំណាងអយ្យការ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវបានផ្លាស់ប្តូរឋានៈរបស់ខ្លួនទៅជាជនត្រូវចោទ។

ជនត្រូវចោទអាចត្រូវបានចៅក្រមស៊ើបសួរដកហូតសិទ្ធិសេរីភាពខ្លះ ដូចជាហាមឃាត់មិនឱ្យផ្លាស់ប្តូរលំនៅឋាន ឬត្រូវមកបង្ហាញខ្លួនតាមការណែនាំរបស់ចៅក្រមស៊ើបសួរ មិនឱ្យធ្វើដំណើរក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរអាទិ៍។[៤២] ឬចៅក្រមស៊ើបសួរ អាចសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្នថែមទៀតផង។ ព្រោះតែអានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនេះនាំឱ្យមានការកំណត់ឋានៈ ជាមធ្យោបាយសម្រាប់ដកហូតសិទ្ធិសេរីភាពចំពោះពលរដ្ឋ ដូចនេះហើយទើបនៅក្នុងបទបញ្ញត្តិនៃមាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានចែងអំពីទម្រង់ចាំបាច់មួយចំនួនដែលតម្រូវឱ្យតំណាងអយ្យការ ដែលជាម្ចាស់បណ្តឹងអាជ្ញាត្រូវតែគោរពជាដាច់ខាតនៅមុនពេលចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅឱ្យចៅក្រមស៊ើបសួរ។

ក្នុងករណីតំណាងអយ្យការចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយបំពានទៅលើទម្រង់ការដែលកំណត់ជាកាតព្វកិច្ចនៅក្នុងមាត្រា៤៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌនាំឱ្យការបើកការស៊ើបសួររបស់តំណាងអយ្យការត្រូវចាត់ទុកជាមោឃៈ ហើយដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរនោះគ្មានអានុភាពអ្វីដល់បុគ្គលដែលមានឈ្មោះនៅក្នុងដីកានោះឡើយ។[៤៣]

**ក.១ ប្រភពដែលនាំឱ្យព្រះរាជអាជ្ញាអាចធ្វើសេចក្តីសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

**ក.១.១ ពាក្យបណ្តឹង ឬពាក្យបរិហារទទួលដោយផ្ទាល់ ឬបញ្ជូនពីមន្ត្រីនគរបាលយុត្តិធម៌**

ដោយយោងតាមមាត្រា១៣១ថ្មីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាបានប្រគល់អំណាចឱ្យតែអង្គការអយ្យការប៉ុណ្ណោះដែលអាចមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ដូច្នេះគ្រប់បុគ្គលឬគ្រប់ស្ថាប័នទាំងអស់នៅពេលដឹងថាមានការកើតឡើងនូវបទល្មើសត្រូវជូនដំណឹងមកស្ថាប័នអយ្យការ ឬប្តឹងចូលមកស្ថាប័នអយ្យការ ឬកសាងសំណុំរឿងបញ្ជូនមកឱ្យស្ថាប័នអយ្យការដើម្បីផ្តើមធ្វើបណ្តឹងអាជ្ញា។

---

[៤១] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១២៥

[៤២] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១២៥ "កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ"

[៤៣] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៤

ជនរងគ្រោះនៃសំណុំរឿងព្រហ្មទណ្ឌក៏ អាចដាក់ពាក្យប្តឹងមកតំណាងអយ្យការបានដែរ។[៤៤] រីឯអ្នកតំណាងរបស់ជនរងគ្រោះ ដែលជាអនីតិជន ឬជានីតិជនស្ថិតនៅក្រោមរបបច្បាប់ការពារ ក៏អាចដាក់ពាក្យប្តឹងមកតំណាងអយ្យការបានដែរ។[៤៥]

ក្នុងករណីផ្សេងទៀតបើសិនជាជនរងគ្រោះទទួលមរណភាព ឬគ្មានអ្នកតំណាងឱ្យខ្លួនទេសិទ្ធិវ័ន្តនៃជនរងគ្រោះ ករណីជនរងគ្រោះទទួលមរណភាពអាចដាក់ពាក្យប្តឹងមកតំណាងអយ្យការបាន។[៤៦] ឬក្នុងករណីជនរងគ្រោះគ្មានអ្នកតំណាងឱ្យខ្លួនទេ ក្រមនីតិវិធីព្រហ្មទណ្ឌដដែលនេះ ក៏បានចែងជាកាតព្វកិច្ចចំពោះអាជ្ញាធរសាធារណៈ ឬមន្ត្រី(មន្ត្រីរាជការ)គ្រប់រូប នៅពេលបំពេញការងាររបស់ខ្លួន ហើយបានដឹងអំពីការកើតឡើងនូវបទល្មើស ត្រូវតែធ្វើបណ្តឹងបរិហារអំពីបទល្មើសដែលខ្លួនបានដឹងនោះមកតំណាងអយ្យការ។[៤៧]

តំណាងអយ្យការថ្លឹងថ្លែងអំពីចំណាត់ការលើពាក្យប្តឹង និងពាក្យបរិហារដែលខ្លួនបានទទួលដោយផ្ទាល់ ឬដែលមន្ត្រីនគរបាលបញ្ជូនមក បន្ទាប់ពីតំណាងអយ្យការបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែមរួចមក ឬអាចនិយាយបានថាពាក្យប្តឹងទាមទារ និងបរិហារដែលខ្លួនទទួលបាននោះគ្រាន់តែជាពាក្យបណ្តឹងសាមញ្ញប៉ុណ្ណោះ គ្មានអានុភាពចាប់បង្ខំឱ្យតំណាងអយ្យការត្រូវតែធ្វើបណ្តឹងអាជ្ញាឡើយ។

បណ្តឹងអាជ្ញានេះអាចធ្វើបានបន្ទាប់ពីតំណាងអយ្យការបានបើកការស៊ើបអង្កេតបឋម ឬបានធ្វើការស្រាវជ្រាវបន្ថែមរួចរាល់ហើយ។ ក្នុងករណីតំណាងអយ្យការសម្រេចធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ តំណាងអយ្យការសុំឱ្យចៅក្រមស៊ើបសួរបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។[៤៨]

**ក.១.២ ការជូនដំណឹងអំពីការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី**

ជនរងគ្រោះនៃបទឧក្រិដ្ឋ ឬបទមជ្ឈិមអាចដាក់ពាក្យប្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលចៅក្រមស៊ើបសួរបាន។ ពាក្យបណ្តឹងនេះមានអានុភាពប្តឹងដល់ចៅក្រមស៊ើបសួរអំពីរឿងហេតុដែលជាបទល្មើសព្រហ្មទណ្ឌ ហើយមានកម្មវត្ថុឱ្យចៅក្រមស៊ើបសួរពិនិត្យ

[៤៤] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៦

[៤៥] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១៥

[៤៦] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១៦

[៤៧] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤២

[៤៨] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤០ និងមាត្រា១២៤

អំពីអត្ថិភាពចំពោះបទល្មើសនោះក្នុងគោលបំណងទទួលបានសំណងការខូចខាតជម្ងឺចិត្ត និងផ្តន្ទាទោសជននោះតាមច្បាប់។

នៅពេលចៅក្រមស៊ើបសួរទទួលបានពាក្យបណ្តឹង ដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរធ្វើការកត់សម្គាល់អំពីការដាក់ពាក្យបណ្តឹងនោះ ហើយបញ្ជូនបណ្តឹងទៅឱ្យតំណាងអយ្យការដើម្បីពិនិត្យ ក្រោយពីបានឃើញពាក្យបណ្តឹងដោយមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនេះ តំណាងអយ្យការអាចប្តឹងសុំទៅចៅក្រមស៊ើបសួរ ឱ្យបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។[៤៩]

**ក.១.៣ អធិបញ្ជារបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌**

កំណត់សម្គាល់៖ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌មានអំណាចអាចធ្វើអធិបញ្ជាឱ្យអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬព្រះរាជអាជ្ញាអមសាលាដំបូងធ្វើការចោទប្រកាន់ចំពោះបទល្មើសព្រហ្មទណ្ឌ ប៉ុន្តែគ្មានអំណាចធ្វើអធិបញ្ជា ឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាតម្កល់រឿងទុកឥតចាត់ការ នូវរឿងក្តីព្រហ្មទណ្ឌណាមួយបានឡើយ។

មាត្រា៧៥នៃច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញាបានបញ្ញត្តិថា រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ គឺជានាយហានានុក្រមនៃអង្គការអយ្យការ ហើយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចធ្វើអធិបញ្ជាតាមការណែនាំជាលាយលក្ខណ៍អក្សរទៅអង្គការអយ្យការគ្រប់ជាន់ថ្នាក់។ នៅក្នុងចំណាត់ការទៅលើសំណុំរឿងក្តីព្រហ្មទណ្ឌវិញ យើងបានមើលឃើញថារដ្ឋមន្ត្រីក្រសួងយុត្តិធម៌អាចប្តឹងបរិហារទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ឬទៅព្រះរាជអាជ្ញាអមសាលាដំបូងអំពីបទល្មើសដែលខ្លួនបានដឹង ឬរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចធ្វើអធិបញ្ជាតាមការណែនាំជាលាយលក្ខណ៍អក្សរ ឱ្យអគ្គព្រះរាជអាជ្ញា ឬព្រះរាជអាជ្ញាអមសាលាដំបូង ធ្វើការចោទប្រកាន់ចំពោះរឿងក្តីព្រហ្មទណ្ឌ ដែលខ្លួនយល់ឃើញថា គឺជាបទល្មើសព្រហ្មទណ្ឌបាន[៥០]។ ក្នុងករណីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ធ្វើអធិបញ្ជាឱ្យចោទប្រកាន់តំណាងអយ្យការត្រូវតែប្តឹងទៅយុត្តាធិការស៊ើបសួរ ឱ្យបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

**ក.១.៤ ការធ្វើអធិបញ្ជារបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍**

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានអំណាចលើចៅក្រមអយ្យការទាំងអស់ដែលស្ថិតនៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន(សមត្ថកិច្ចដែនដីនាពេលបច្ចុប្បន្នគឺ គ្រប់អយ្យការអមសាលាដំបូងនៅក្នុងព្រះរាជាណាចក្រកម្ពុជាទាំងអស់)។ ក៏ប៉ុន្តែនៅពេលច្បាប់ស្តីពីការរៀបចំអង្គការតុលាការដំណើរការ

[៤៩] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១៣៩

[៥០] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា២៩

បានអយ្យការអមសាលាឧទ្ធរណ៍ត្រូវបានបង្កើតឡើងច្រើនជាងមួយ គឺមានអយ្យការអមសាលាឧទ្ធរណ៍នៅរាជធានីភ្នំពេញ និងអយ្យការអមសាលាឧទ្ធរណ៍នៅតាមតំបន់)[៥១]។

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចធ្វើអធិបញ្ញាឱ្យព្រះរាជអាជ្ញាអមសាលាដំបូងធ្វើការចោទប្រកាន់។ ព្រះរាជអាជ្ញាដែលមានកាតព្វកិច្ចត្រូវគោរពតាមអធិបញ្ញានេះ ត្រូវបើកការស៊ើបសួរតាមរយៈដីកាសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរ។

**ក.១.៥ ការស្នើសុំឱ្យបើកការស៊ើបសួរបន្ថែម**

នៅពេលបំពេញកិច្ចស៊ើបសួរ ប្រសិនបើមានលេចនូវអង្គហេតុថ្មីដែលអាចជាបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនេះទៅតំណាងអយ្យការដោយដីកាប៉ុន្តែមិនមែនជាដីកាសម្រេចទេ។ តំណាងអយ្យការអាចប្ដឹងសុំឱ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរចំពោះអង្គហេតុថ្មីនោះតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម។ ក្នុងករណីចៅក្រមស៊ើបសួរមិនទទួលបានដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។[៥២]

**ក.១.៦ ការបញ្ជូនរឿងឱ្យបើកការស៊ើបសួរដោយចៅក្រមជំនុំជម្រះ**

តំណាងអយ្យការអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលទៅបង្ហាញខ្លួនភ្លាម នៅមុខតុលាការជាន់ដំបូងប្រសិនបើមានគ្រប់លក្ខខណ្ឌដែលមានចែងក្នុងមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ប៉ុន្តែប្រសិនបើតុលាការដែលបានទទួលបណ្ដឹង តាមនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមយល់ឃើញថាល័ក្ខខ័ណ្ឌនៃមាត្រា៤៧ នៃក្រមនេះមិនបានបំពេញទេ ឬក៏ដោយភាពស្មុកស្មាញនៃសំណុំរឿងដែលតម្រូវជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានស៊ីជម្រៅបន្ថែមទៀត តុលាការជំនុំជម្រះនៃនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមត្រូវបញ្ជូនសំណុំរឿងទៅតំណាងអយ្យការ ដើម្បីបើកការស៊ើបសួរវិញ តំណាងអយ្យការប្ដឹងសុំដើម្បីបើកការស៊ើបសួរតាមដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅចៅក្រមស៊ើបសួរហើយ ជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួនចំពោះមុខចៅក្រមស៊ើបសួរនៅថ្ងៃនោះតែម្ដង បើមិនដូច្នោះទេជនជាប់ចោទត្រូវតែដោះលែងឱ្យមានសេរីភាពវិញដោយឯកឯង។[៥៣]

**ក.២ ល័ក្ខខ័ណ្ឌចាំបាច់ដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ**

**ករណីបទឧក្រិដ្ឋ**

[៥១] ច្បាប់ស្ដីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ មាត្រា៤០

[៥២] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១២៥ កឋាខណ្ឌទី២

[៥៣] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៨ និងមាត្រា៣០៤

យោងតាមមាត្រា៤៦នៃក្រមព្រហ្មទណ្ឌបានឱ្យនិយមន័យថាបទឧក្រិដ្ឋ គឺជាបទល្មើសដែលនៅក្នុងករណីដែលអតិបរមានៃទោសដាក់ពន្ធនាគារ ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត ឬជាទោសដាក់ពន្ធនាគារមានរយៈពេលលើសពី៥ឆ្នាំ និងក្រោម ឬស្មើនឹង៣០ឆ្នាំ និងទោសដាក់ពន្ធនាគារអាចត្រូវបន្ថែមនូវទោសពិន័យជាប្រាក់ផងដែរ។ មាត្រានេះបញ្ជាក់ឱ្យឃើញថាបទឧក្រិដ្ឋគឺជាបទល្មើសដែលមានស្ថានភាពធ្ងន់ធ្ងរ មានផលប៉ះពាល់ខ្លាំងដល់សង្គម និងមានរយៈពេលវែងក្នុងការដកហូតសិទ្ធិសេរីភាពរបស់បុគ្គល ដូច្នេះតម្រូវឱ្យត្រូវពិនិត្យឱ្យបានល្អិតល្អន់បំផុត មុននឹងធ្វើការសម្រេចអំពីទោស។ ព្រោះតែស្ថានភាពធ្ងន់ធ្ងរដែលកើតឡើងពីបទល្មើសនោះទើបក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិជាកាតព្វកិច្ចជាចាំបាច់ថា ក្នុងករណីបទល្មើសជាបទឧក្រិដ្ឋតំណាងអយ្យការត្រូវតែបើកការស៊ើបសួរ[៥៤]។

**ករណីបទមជ្ឈិម**

ចំណែកឯបទមជ្ឈិមវិញ មិនមែនជាល័ក្ខខ័ណ្ឌចាំបាច់ដែលតម្រូវឱ្យព្រះរាជអាជ្ញាត្រូវតែប្តឹងសុំចោទប្រកាន់ឱ្យបើកការស៊ើបសួរឡើយ[៥៥]។ ព្រះរាជអាជ្ញាមានជម្រើសផ្សេងៗដូចជាប្រើនីតិវិធីប្តឹងសុំទៅយុត្តាធិកាជំនុំជម្រះដោយបញ្ជូនជនសង្ស័យទៅជំនុំជម្រះតែម្តង ឬធ្វើការតម្កល់រឿងទុកឥតចាត់ការ។

ករណីដែលបទមជ្ឈឹមតម្រូវអោយបើកការស៊ើបសួរ គឺលុះត្រាតែភស្តុតាងដែលប្រមូលបាននោះពុំទាន់គ្រប់គ្រាន់ដើម្បីប្តឹងទៅយុត្តាធិការជំនុំជម្រះបាន ហើយភស្តុតាងដែលខ្វះខាតមិនអាចប្រមូលបាន ដោយការស៊ើបអង្កេតបឋម ប៉ុន្តែអាចប្រមូលបានក្នុងករណីដែលត្រូវប្រើអំណាចដោយបង្ខំ ឬក្នុងករណីដែលបទមជ្ឈឹមនោះមានលក្ខណៈស្មុគស្មាញ ដែលតម្រូវអោយមានការស្រាវជ្រាវយូរ និងមានការលំបាកក្នុងការស្រាវជ្រាវ។

**ក.៣ អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ**

អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាការប្តឹងសុំទៅយុត្តាធិកាស៊ើបសួរឱ្យដាក់ស្ថិតក្រោមការពិនិត្យចំពោះបុគ្គលម្នាក់ ឬច្រើននាក់ដោយមានចង្អុលប្រាប់ឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ឬបានដាក់ឱ្យស្ថិតក្រោមការពិនិត្យចំពោះអញ្ញាតជនដែលតំណាងអយ្យការធ្វើសេចក្តីសន្និដ្ឋានថាបានប្រព្រឹត្តបទល្មើសដោយផ្ទាល់ ឬបានចូលរួមប្រព្រឹត្តបទល្មើស។[៥៦]

---

[៥៤] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៤

[៥៥] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៥

[៥៦] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១២៤ និងមាត្រា១៤៣

ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ គឺជាមូលដ្ឋានដែលផ្តល់អំណាចដល់ចៅក្រមស៊ើបសួរនៅក្នុងបេសកម្មស្វែងរកយុត្តិធម៌ ឬម្យ៉ាងទៀតថាជាអំណាចក្នុងការពិនិត្យអំពីអត្ថិភាពនៃបទល្មើស។ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ បានផ្តល់អំណាចឱ្យចៅក្រមស៊ើបសួរអាចដកហូតសិទ្ធិសេរីភាពមួយចំនួនចំពោះបុគ្គលដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។

ការដកហូតសិទ្ធិសេរីភាពនោះមានជាអាទិ៍ដូចជា ការឃុំខ្លួនបណ្តោះអាសន្នដោយឈរលើមូលហេតុដែលមានបញ្ញត្តិក្នុងមាត្រា២០៥នៃក្រមនីតិវិធីព្រហ្មទណ្ឌ និងសិទ្ធិអំណាចក្នុងការដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការពិនិត្យតាមផ្លូវតុលាការ ដែលមានបញ្ញត្តិក្នុងមាត្រា២២៣នៃក្រមនីតិវិធីព្រហ្មទណ្ឌ។[៥៧]

**ខ.ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់**

នីតិវិធីនៃការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏ជាជម្រើសមួយរបស់តំណាងអយ្យការក្នុងការចោទប្រកាន់ខាងបទល្មើសព្រហ្មទណ្ឌផងដែរ។ នីតិវិធីថ្មីនេះទើបតែបង្កើតឡើងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌថ្មីឆ្នាំ២០០៧នេះតែប៉ុណ្ណោះក្រមនីតិវិធីនេះ ធ្វើការណែនាំឱ្យតំណាងអយ្យការត្រូវតែប្រើនីតិវិធីបញ្ជូនទៅជម្រះផ្ទាល់ចំពោះបទលហុ[៥៨] ឬអាចប្រើនីតិវិធីបញ្ជូនទៅជម្រះផ្ទាល់ចំពោះបទមជ្ឈិមដែលមានភស្តុតាងគ្រប់គ្រាន់ហើយមិនមែនជាសំណុំរឿងមជ្ឈិមស្មុកស្មាញ[៥៩]។

**ខ.១ លក្ខខណ្ឌទម្រង់ និងរយៈពេល**

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺជាបញ្ជាឱ្យជនជាប់ចោទឱ្យចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូង ហើយដើម្បីអាចចេញដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បាន លុះត្រាតែបានបំពេញនូវលក្ខខ័ណ្ឌពីរគឺល័ក្ខខ័ណ្ឌទម្រង់ និងល័ក្ខខ័ណ្ឌនៃរយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងរយៈពេលដែលបង្គាប់ឱ្យចូលមកបង្ហាញខ្លួនចំពោះមុខតុលាការ។

ល័ក្ខខ័ណ្ឌទម្រង់នៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់រួមមាន[៦០] ៖

- អត្តសញ្ញាណនៃជនជាប់ចោទ
- សេចក្តីសង្ខេបនៃអង្គហេតុ

---

[៥៧] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា ២០៤ មាត្រា ២០៥ និង មាត្រា២២៣

[៥៨] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៩

[៥៩] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៥

[៦០] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៦ និងមាត្រា៤៥៦

- ឈ្មោះបទល្មើស

- អត្ថបទច្បាប់ដែលកំណត់ និងបង្រាបបទល្មើស។

- ការចង្អុលប្រាប់ពីតុលាការ ព្រមទាំទីកន្លែង កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការ

លក្ខខ័ណ្ឌនៃរយៈពេលដែលត្រូវគោរពក្នុងការចេញដីកា[៦១]

រយៈពេលដែលត្រូវគោរព រវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់ ឱ្យដល់ជនជាប់ចោទ និងថ្ងៃកំណត់ឱ្យចូលបង្ហាញខ្លួននៅមុខតុលាការ ត្រូវកំណត់ដូចតទៅៈ

- ១៥ (ដប់ប្រាំ) ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃទីស្នាក់ការរបស់តុលាការ

- ២០ (ម្ភៃ) ថ្ងៃ ប្រសិនបើជនជាប់ចោទ រស់នៅក្នុងទីកន្លែងផ្សេងក្នុងដែនដីជាតិ

- ២ (ពីរ) ខែ ប្រសិនបើជនជាប់ចោទ រស់នៅក្នុងរដ្ឋមួយជាប់ព្រំដែនព្រះរាជាណាចក្រកម្ពុជា

- ៣ (បី) ខែ ប្រសិនបើជនជាប់ចោទ រស់នៅក្នុងទីកន្លែងដទៃផ្សេងទៀត។

ដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់ អាចត្រូវប្រគល់ឱ្យជនជាប់ចោទដោយៈ

- ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ក៏អាចត្រូវប្រគល់ឱ្យជនជាប់ចោទដោយអាជ្ញាសាលាផងដែរ។ អាជ្ញាសាលាត្រូវប្រើប្រាស់គ្រប់មធ្យោបាយដើម្បីប្រគល់ដីកានេះឱ្យជនជាប់ចោទដោយផ្ទាល់ដៃ[៦២]។ អាជ្ញាសាលាប្រគល់ចុងដីកាកោះទៅឱ្យជនជាប់ចោទ ហើយអាជ្ញាសាលាចារសេចក្តីលើដើមដីកាថាបានប្រគល់ចុងដីកាដល់ជនជាប់ចោទដោយផ្ទាល់ដៃ ហើយចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ ទីកន្លែងប្រគល់ដីកា និងមានចុះហត្ថលេខានៅលើដើមដីកានោះ។ ដើមដីកាត្រូវបញ្ជូនវិលត្រឡប់ទៅតំណាងអយ្យការវិញភ្លាម[៦៣]។

ក្នុងករណីជនជាប់ចោទអវត្តមានពីលំនៅឋានរបស់ខ្លួន អាជ្ញាសាលាត្រូវប្រគល់ចុងដីកាឱ្យដល់គ្រប់បុគ្គលទាំងឡាយណាជា នីតិជនដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទនោះ។ បុគ្គលដែលទទួលដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ត្រូវសន្យាថានឹងប្រគល់ដីកានោះក្នុងរយៈពេលខ្លីបំផុតដល់ជនជាប់ចោទ។ អាជ្ញាសាលាចុះនិទ្ទេសស្តីពីអត្តសញ្ញាណនៃបុគ្គលដែលទទួលចុងដីកាកោះចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ និងទីកន្លែងប្រគល់ដីកាហើយមានចុះហត្ថលេខានៅលើដើមដីកានោះ ហើយដើមដីកាត្រូវបញ្ជូនវិលត្រឡប់ទៅតំណាងអយ្យការវិញភ្លាម[៦៤]។

---

[៦១] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៥៧

[៦២] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៥៩

[៦៣] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៦០

[៦៤] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៦១

អាជ្ញាសាលាត្រូវប្រគល់ចុងដីកាកោះឱ្យដល់មេឃុំ ឬចៅសង្កាត់ ឬជំទប់ ឬចៅសង្កាត់រង ក្នុងករណីផ្សេងទៀតដូចជា៖

+ ជនជាប់ចោទមិនព្រមទទួលដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់

+ គ្មានវត្តមានបុគ្គលណាម្នាក់ជានីតិជននៅក្នុងលំនៅឋានរបស់ជនជាប់ចោទទេ

+ គ្មានបុគ្គលណាម្នាក់ជានីតិជន ដែលមានវត្តមាននៅក្នុងលំនៅឋានរបស់ជនជាប់ចោទព្រមទទួលដីកាកោះនោះទេ។[៦៥]

- ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ អាចត្រូវប្រគល់ឱ្យជនជាប់ចោទដោយផ្ទាល់ដៃដោយតំណាងអយ្យការ។ តំណាងអយ្យការប្រគល់ចុងដីកាទៅឱ្យជនជាប់ចោទហើយតំណាងអយ្យការចុះនិទ្ទេសស្តីពីកាលបរិច្ឆេទ ទីកន្លែងប្រគល់ដីកា និងមានចុះហត្ថលេខានៅលើដើមដីកានោះ[៦៦]។

- មានមធ្យោបាយផ្សេងទៀតទាក់ទងនឹងការកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ គឺមានដូចជា៖

+ ការបញ្ជូនតាមផ្លូវរដ្ឋបាល

+ ការបញ្ជូនតាមរយៈក្រឡាបញ្ជី

+ ការបញ្ជូនតាមរយៈអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។[៦៧]

+ ការបញ្ជូនតាមរយៈប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ប្រសិនបើជនជាប់ចោទត្រូវឃុំខ្លួនពីបទល្មើសផ្សេងទៀត។

**ខ.២ មូលហេតុនៃការប្រើនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់**

**ខ.២.១ បទលហុ**

បទលហុ គឺជាបទល្មើសដែលអតិបរមានៃការផ្តន្ទាទោសដាក់ពន្ធនាគារមានរយៈពេលក្រោម ឬស្មើ០៦ថ្ងៃ ឬជាប្រភេទបទល្មើសដែលគ្រាន់តែត្រូវផ្តន្ទាទោសពិន័យជាប្រាក់តែប៉ុណ្ណោះ។[៦៨] ព្រោះតែបទល្មើសលហុត្រូវបានចាត់ទុកថាជាប្រភេទបទល្មើសស្រាលបំផុត ដែលមិនបង្កឱ្យប៉ះពាល់ដល់សន្តិសុខសង្គមហើយដើម្បីកាត់បន្ថយបន្ទុកចំណាយរបស់រដ្ឋ និងភាគី និងដើម្បីចំណេញពេលវេលាទើបច្បាប់បានបញ្ញត្តិជាកំហិតថា ក្នុងករណីទទួលបានសំណុំរឿងដែលជាបទលហុ តំណាងអយ្យការត្រូវតែប្រើនីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់។[៦៩]

---

[៦៥] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៦២

[៦៦] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៥៨

[៦៧] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៦៣

[៦៨] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា៤៨

[៦៩] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៩

**ខ.២.២ បទមជ្ឈិម**

តំណាងអយ្យការមានកាតព្វកិច្ចត្រូវតែគោរព តែចំពោះលក្ខខណ្ឌតែ០២(ពីរ)តែប៉ុណ្ណោះ។ គឺមាត្រា៩៤នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបញ្ញត្តិថា ព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរចំពោះបទឧក្រិដ្ឋ និងមាត្រា៩៩នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលបញ្ញត្តិថា ព្រះរាជអាជ្ញាត្រូវតែប្រើនីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ចំពោះបទលហុ។

ចំណែកឯការបញ្ជូនទៅជំនុំជម្រះផ្ទាល់ចំពោះបទមជ្ឈិម ច្បាប់មិនបានតម្រូវថាត្រូវតែធ្វើបែបណានោះទេ។ ចំពោះករណីបទល្មើសមជ្ឈិមក៏បានដែរទោះបីជាបទល្មើសនោះជាបទមជ្ឈិមជាក់ស្តែងឬមិនជាក់ស្តែងក៏ដោយ។ ដូច្នេះតំណាងអយ្យការមានជម្រើសអាចប្រើនីតិវិធីកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់បាន។

**ខ.៣ អានុភាពនៃដីកាកោះហៅទៅជំនុំជម្រះផ្ទាល់**

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ មានអានុភាពជាការប្តឹងសុំទៅយុត្តាធិកាជំនុំជម្រះឱ្យបើកសវនាការទៅតាមកាលបរិច្ឆេទដែលកំណត់ នៅក្នុងដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ដើម្បីជំនុំជម្រះលើអង្គសេចក្តីចំពោះបទលហុ ឬបទមជ្ឈិមដែលមានលក្ខណៈគ្រប់ជ្រង់ជ្រោយ។ យោងតាមមាត្រា៩៦នៃក្រមនីតិវិធីព្រហ្មទណ្ឌ កាលបរិច្ឆេទ និងម៉ោងពេលនៃសវនាការត្រូវកំណត់ឡើងដោយតំណាងអយ្យការនៅក្នុងដីកាកោះហៅបញ្ជូនទៅជម្រះផ្ទាល់តែម្តង។ ដោយសារផ្អែកលើមូលហេតុដូច្នេះហើយ ទើបយើងយល់ថាអានុភាពនៃដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះបានបំពានទៅលើសិទ្ធិអំណាចរបស់ប្រធានសាលដំបូង ដែលពីដំបូងជាបុគ្គលតែម្នាក់គត់ដែលមានអំណាចកំណត់អំពីកាលបរិច្ឆេទនៃសវនាការ។

ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ មានអានុភាពកែប្រែឋានៈរបស់បុគ្គលធម្មតាម្នាក់ឱ្យក្លាយទៅជាជនជាប់ចោទ។ មិនតែប៉ុណ្ណោះដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់នេះថែមទាំងមានអានុភាពជាសេចក្តីបញ្ជាដល់ជនជាប់ចោទនោះ ឱ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ដំបូងដែលចេញដីកាកោះនោះថែមទៀតផង។

**គ. កំណត់ហេតុស្តីពីនីតិវិធីបង្ហាញខ្លួនភ្លាម**

ក្រមនីតិវិធីព្រហ្មទណ្ឌថ្មីនៃព្រះរាជាណាចក្រកម្ពុជាបានបង្កើតមធ្យោបាយថ្មីមួយទៀត ហៅថានីតិវិធីបង្ហាញខ្លួនភ្លាម ដែលផ្តល់សិទ្ធិអំណាចឱ្យតំណាងអយ្យការអាចប្តឹងសុំចោទប្រកាន់ទៅឱ្យយុត្តាធិកាជំនុំជម្រះធ្វើការជំនុំជម្រះចំពោះអំពើដែលតំណាងអយ្យការយល់ថាជាបទល្មើសតែម្តង។

កាលណាតំណាងអយ្យការសម្រេចប្រើនីតិវិធីបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម សេចក្តីសម្រេចនោះមានអានុភាពបញ្ជាទៅដល់កំលាំងសាធារណៈ ដែលមានសមត្ថកិច្ចឱ្យនាំខ្លួនជនជាប់ចោទចូល

បង្ហាញខ្លួននៅមុខតុលាការជាន់ដំបូងភ្លាម បន្ទាប់ពីផ្ទៀងផ្ទាត់អត្តសញ្ញាណជនជាប់ចោទរួចរាល់ហើយ តុលាការដែលទទួលបន្ទុកជំនុំជម្រះត្រូវបើកសវនាការនៅថ្ងៃនោះតែម្តង។

នីតិវិធីបង្ហាញខ្លួនភ្លាមនេះគឺជានីតិវិធីថ្មី ដែលស្តែងឱ្យឃើញអំពីការបង្កើនល្បឿនចំពោះចំណាត់ការរឿងក្តីរបស់ស្ថាប័នតុលាការ ដែលជម្រុញឱ្យការស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋបានឆាប់រហ័ស។ ប៉ុន្តែពេលខ្លះមានការយល់ឃើញថា ការធ្វើឱ្យឆាប់រហ័សពេកក៏បានប៉ះពាល់ដល់សិទ្ធិរបស់ភាគីនៃរឿងក្តីផងដែរ។ ហេតុដូច្នេះហើយទើបច្បាប់បានបញ្ញត្តិអំពីលក្ខខណ្ឌមួយចំនួន ដែលតម្រូវឱ្យអ្នកអនុវត្តត្រូវតែគោរពផងដែរ។

**គ.១ លក្ខខណ្ឌដើម្បីប្រើនីតិវិធីបង្ហាញខ្លួនភ្លាម**

តំណាងអយ្យការអាចប្រើនីតិវិធីបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលបង្ហាញខ្លួនភ្លាមបាន លុះត្រាតែសំណុំរឿងក្តីដែលខ្លួនទទួលបាននោះ បំពេញតាមលក្ខខណ្ឌទាំងបួនដែលបញ្ញត្តិនៅក្នុងមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**គ.១.១ លក្ខខណ្ឌបទល្មើស**

តំណាងអយ្យការអាចប្រើនីតិវិធីបង្គាប់ឱ្យនាំជនជាប់ចោទទៅបង្ហាញខ្លួនបាន លុះត្រាតែអំពើដែលប្រព្រឹត្តនោះគឺជាបទល្មើសជាក់ស្តែង [៧០] បទល្មើសជាក់ស្តែងមានប្រភេទជាបទមជ្ឈិមដែលអតិបរមានៃការផ្តន្ទាទោសយ៉ាងតិច១ឆ្នាំ ឬអតិបរមានៃការផ្តន្ទាទោសយ៉ាងច្រើនក្រោមឬស្មើ០៥ឆ្នាំ។ ជាបទល្មើសជាក់ស្តែងដែលបំពេញលក្ខខណ្ឌមានបញ្ញត្តិក្នុងមាត្រា៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលផ្តល់សិទ្ធិអំណាចឱ្យតុលាការជំនុំជម្រះអាចចេញ ដីកាបង្គាប់ឱ្យឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនជាប់ចោទនៅក្នុងសវនាការបាន។

នីតិវិធីបង្ហាញខ្លួនភ្លាមនេះអាច ប្រើបានតែចំពោះករណីជាបទល្មើសជាក់ស្តែងហើយដែលជនជាប់ចោទកំពុងស្ថិតនៅក្នុងការឃាត់ខ្លួនចំពោះបទល្មើសនោះតែប៉ុណ្ណោះ។ ក្នុងករណីផ្សេងទៀតដែលក្រៅពីករណីខាងលើនេះ តំណាងអយ្យការអាចធ្វើនីតិវិធីប្តឹងសុំឱ្យបើកការស៊ើបសួរតាមរយៈនីតិវិធីធម្មតា ឬនីតិវិធីបញ្ជូនទៅជំនុំជម្រះផ្ទាល់។

**គ.១.២ លក្ខខណ្ឌចំពោះការផ្តន្ទាទោស**

ល័ក្ខខ័ណ្ឌចាំបាច់ទីពីរដែលតម្រូវឱ្យមាន គឺត្រូវតែជាបទល្មើសមជ្ឈិមដែលអតិបរមានៃការផ្តន្ទាទោសចំពោះបទល្មើសនោះត្រូវដាក់ពន្ធនាគារយ៉ាងតិច០១(មួយ)ឆ្នាំ និងអតិបរមានៃការផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងច្រើន ០៥ (ប្រាំ)ឆ្នាំ។[៧១]

---

[៧០] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៧

[៧១] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៧

មូលទោសនៃមាត្រា៣៨៤ នៃក្រមព្រហ្មទណ្ឌ "បទបន្លំ" បញ្ញត្តិឱ្យផ្តន្ទាទោសដាក់ពន្ធនាគារពី ០៦ថ្ងៃ ទៅ ៣ខែ និងពិន័យជាប្រាក់ពី១០០.០០០ (មួយសែន)រៀលទៅ៥០០.០០០(ប្រាំសែន)រៀល។ មានសំណួរសួរថាៈក្នុងករណីទទួលបានសំណុំរឿង "បទបន្លំ" តើតំណាងអយ្យការអាចប្រើនីតិវិធីបង្ហាញខ្លួនភ្លាមបានដែរឬទេ?

អតិបរមានៃការផ្តន្ទាទោសដាក់ពន្ធនាគារនៃបទបន្លំ មានរយៈពេលត្រឹមតែ៣ខែប៉ុណ្ណោះហេតុដូច្នេះ តំណាងអយ្យការមិនអាចប្រើនីតិវិធីបង្ហាញខ្លួនភ្លាមចំពោះករណីនេះឡើយ។ ព្រោះលក្ខខណ្ឌចាំបាច់ដែលតម្រូវឱ្យតំណាងអយ្យការ អាចប្រើនីតិវិធីបង្ហាញខ្លួនភ្លាមបានលុះត្រាតែអតិបរមានៃការផ្តន្ទាទោសចំពោះបទល្មើសយ៉ាងតិចមានរយៈពេល១ឆ្នាំ។

**គ.១.៣ លក្ខខណ្ឌអាយុ**

ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាដែលបានពន្យល់ថា បុគ្គលដែលអាចទទួលខុសត្រូវព្រហ្មទណ្ឌបានលុះត្រាតែជននោះដល់នីតិភាព។ ហើយនីតិភាពដែលកំណត់យកនៅក្នុងក្រមព្រហ្មទណ្ឌគឺមានអាយុចាប់ពី១៨ឆ្នាំឡើងទៅ[៧២] ក៏ប៉ុន្តែក្រមនេះក៏បានបញ្ញត្តិផងដែរថាតុលាការព្រហ្មទណ្ឌនៅតែអាចប្រកាសអំពីទណ្ឌកម្មទៅលើអនីតិជននោះបានដែរ ក្នុងករណីដែលគេមានអាយុដល់១៤ឆ្នាំហើយ ប្រសិនបើគេបានទៅប្រព្រឹត្តបទល្មើស។ ការប្រកាសអំពីទណ្ឌកម្មទៅលើអនីតិជនត្រូវតែផ្អែកទៅលើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជននោះតម្រូវ។[៧៣] ចំពោះការអនុវត្តជាក់ស្តែងតុលាការតែងតែប្រើវិធានការអប់រំណែនាំ ចំពោះការប្រព្រឹត្តបទល្មើសតូចតាចរបស់អនីតិជន។

ចំណុចទី៣ នៃមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌបានបញ្ញត្តិថាតំណាងអយ្យការអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលទៅបង្ហាញខ្លួនភ្លាម នៅចំពោះមុខតុលាការជាន់ដំបូងឱ្យធ្វើការជំនុំជម្រះភ្លាមៗបានប្រសិនបើជនជាប់ចោទនោះគឺជានីតិជន។

**គ.១.៤ លក្ខខណ្ឌសំណុំរឿង**

លក្ខខណ្ឌមួយទៀតដែលតម្រូវឱ្យមានដើម្បីបើកផ្លូវឱ្យតំណាងអយ្យការ អាចប្រើនីតិវិធីបង្ហាញខ្លួនភ្លាមបាន គឺជាលក្ខខណ្ឌនៃសំណុំរឿងមានន័យថាលុះត្រាតែសំណុំរឿននោះមានលក្ខណៈគ្រប់គ្រាន់ល្មមអាចជំនុំជម្រះបានទើប តំណាងអយ្យការអាចបញ្ជូនសំណុំរឿងនោះទៅជំនុំជម្រះភ្លាមបាន។[៧៤]

---

[៧២] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា៣៨

[៧៣] ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ មាត្រា៣៩ កឋាខណ្ឌទី២

[៧៤] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៧ ចំនុចទី៤

**គ.២ នីតិវិធីនៃការបង្ហាញខ្លួនភ្លាម**

នៅពេលមន្ត្រីនគរបាលយុត្តិធម៌បានបញ្ជូនសំណុំរឿង និងបញ្ជូនខ្លួនបុគ្គលដែលត្រូវបានឃាត់ខ្លួនមកឱ្យតំណាងអយ្យការ តំណាងអយ្យការអាចបង្គាប់ឱ្យនាំខ្លួនជនជាប់ចោទចូលទៅបង្ហាញខ្លួននៅមុខតុលាការជាន់ដំបូងបាន បន្ទាប់ពីបានពិនិត្យឃើញថាសំណុំរឿងក្តីព្រហ្មទណ្ឌនោះបានបំពេញគ្រប់លក្ខខណ្ឌដែលមានបញ្ញត្តិនៅក្នុងមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

កាលណាសម្រេចថាត្រូវប្រើនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម តំណាងអយ្យការត្រូវពិនិត្យអត្តសញ្ញាណបុគ្គលដែលគេបញ្ជូនមកឱ្យខ្លួន។ ឱ្យដំណឹងដល់ជននោះអំពីរឿងរ៉ាវ និងបទល្មើសដែលចោទប្រកាន់ និងប្រាប់អំពីសិទ្ធិដល់ជននោះថាខ្លួនអាចពឹងមានមេធាវីការពារខ្លួនបាន។ តំណាងអយ្យការទទួលស្តាប់ចម្លើយ ក្នុងករណីបុគ្គលដែលនឹងត្រូវនាំទៅបង្ហាញខ្លួនភ្លាមនោះចង់និយាយ។ តំណាងអយ្យការគ្រាន់តែធ្វើការកត់សម្គាល់ ចំពោះចម្លើយដែលជននោះបានរៀបរាប់តែប៉ុណ្ណោះ។

តំណាងអយ្យការ ធ្វើបណ្តឹងសុំឱ្យជំនុំជម្រះទៅយុត្តាធិកាជំនុំជម្រះនៃតុលាការជាន់ដំបូងតាមរយៈកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាម។ ក្នុងករណីសម្រេចថាត្រូវប្រើនីតិវិធីបង្ហាញខ្លួនភ្លាម តំណាងអយ្យការកំណត់កាលបរិច្ឆេទនៃសវនាការ នៅក្នុងកំណត់ហេតុស្តីពីការបង្គាប់ឱ្យចូលបង្ហាញខ្លួនភ្លាមនោះតែម្តង។[៧៥] បន្ទាប់មកទៀតតំណាងអយ្យការត្រូវកោះហៅជនរងគ្រោះ សាក្សី អ្នកបកប្រែ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដើមបណ្តឹងរដ្ឋប្បវេណីឱ្យចូលរួមសវនាការផងដែរ។

នីតិវិធីបង្ហាញខ្លួនភ្លាមនេះ បានផ្លាស់ប្តូរឋានៈបុគ្គលដែលបញ្ជូនមកនោះទៅជាជនជាប់ចោទ។ ជនជាប់ចោទត្រូវបង្ខាំងទុកដោយមានកងកម្លាំងការពារ រហូតដល់សាមីខ្លួនចូលទៅបង្ហាញខ្លួននៅចំពោះមុខតុលាការជាន់ដំបូង។ តុលាការដែលទទួលបានបណ្តឹងតាមនីតិវិធីបង្ហាញខ្លួនភ្លាមនេះត្រូវបើកសវនាការជំនុំជម្រះលើអង្គសេចក្តីនៅក្នុងថ្ងៃនោះតែម្តង។ លើកលែងតែជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថារឿងក្តីមិនទាន់អាចជំនុំជម្រះភ្លាមៗបាន។

នៅមុនពេលចាប់ផ្តើមដំណើរការជំនុំជម្រះ តុលាការជាន់ដំបូងត្រូវធ្វើរបាយការណ៍សង្ខេបអំពីរឿងរ៉ាវដែលតំណាងអយ្យការបានចោទប្រកាន់ ហើយប្រាប់ជនជាប់ចោទអំពីសិទ្ធិរបស់ខ្លួនដែលអាចមានមេធាវីការពារ និងប្រាប់អំពីសិទ្ធិអាចស្នើសុំរយៈពេល ដើម្បីរៀបចំខ្លួនមុនពេលទទួលបានការជំនុំជម្រះ។ តុលាការជំនុំជម្រះអាចចេញសាលក្រមមុនអង្គសេចក្តី ដើម្បីផ្តល់រយៈពេលឱ្យជនជាប់ចោទចំនួន០២(ពីរ)សប្តាហ៍ដើម្បីរៀបចំខ្លួន។ សាលក្រមមុនអង្គសេចក្តីនេះ ក៏ត្រូវសម្រេចអំពីការឃុំ

[៧៥] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា២៩២

ខ្លួនបណ្ដោះអាសន្នចំពោះជនជាប់ចោទ ដោយផ្អែកតាមមូលហេតុដែលមានបញ្ញត្តិនៅក្នុងមាត្រា២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌផងដែរ។

សាលក្រមលើអង្គសេចក្ដីត្រូវប្រកាសភ្លាម បន្ទាប់ពីបញ្ចប់ការពិភាក្សាដេញដោលនៅក្នុងសវនាការ ឬត្រូវតែប្រកាលក្នុងរយៈពេលមិនលើសពី០២(ពីរ)សប្ដាហ៍ គិតចាប់ពីថ្ងៃដែលជនជាប់ចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ។ ក្នុងករណីជនជាប់ដែលស្ថិតនៅក្នុងការឃុំខ្លួនបណ្ដោះអាសន្នមិនទទួលបានការសម្រេចលើអង្គសេចក្ដីក្នុងរយៈពេលនោះទេ ជនជាប់ចោទត្រូវតែមានសេរីភាពដោយពេញច្បាប់។[៧៦]

ប្រសិនបើតុលាការដែលបានទទួលបណ្ដឹងតាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាម យល់ឃើញថាលក្ខខណ្ឌនៃមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌមិនបានបំពេញទេ ឬក៏ដោយសារភាពសាំញ៉ាំនៃរឿងក្ដីតម្រូវជាចាំបាច់ឱ្យធ្វើការស្រាវជ្រាវឱ្យបានជ្រាលជ្រៅបន្ថែមទៀត តុលាការត្រូវបញ្ជូនសំណុំរឿងទៅតំណាងអយ្យការឱ្យបើកការស៊ើបសួរវិញ។ តំណាងអយ្យការប្ដឹងសុំទៅចៅក្រមស៊ើបសួរតាមរយៈដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ។ ហើយជនជាប់ចោទត្រូវតែនាំទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរនៅថ្ងៃនោះតែម្ដង បើមិនដូច្នោះទេជនជាប់ចោទត្រូវតែទទួលបានការដោះលែងនៅថ្ងៃនោះតែម្ដង។

**គ.៣ អានុភាពនៃកំណត់ហេតុបង្ហាញខ្លួនភ្លាម**

**គ.៣.១ ឱ្យតុលាការបើកសវនាការនៅថ្ងៃនោះតែម្ដង**

តុលាការជាន់ដំបូង ដែលទទួលបណ្ដឹងតាមរយៈកំណត់ហេតុស្ដីពីការបង្ហាញខ្លួនភ្លាមត្រូវតែបើកសវនាការ ជំនុំជម្រះនៅថ្ងៃនោះតែម្ដង។

**គ.៣.២ ត្រូវតែចេញសាលក្រមនៅថ្ងៃនោះតែម្ដង**

តុលាការជាន់ដំបូងនោះត្រូវតែចេញសាលក្រមលើអង្គសេចក្ដីនៅថ្ងៃនោះតែម្ដង លើកលែងតែជនជាប់ចោទសុំរយៈពេលដើម្បីរៀបចំការពារខ្លួន ឬបើតុលាការយល់ថាសំណុំរឿងក្ដីមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេទើបតុលាការអាចចេញសាលក្រមមុនអង្គសេចក្ដី ហើយលើកពេលសវនាការទៅពេលក្រោយវិញបាន។[៧៧]

**គ.៣.៣ អានុភាពឱ្យព្រះរាជអាជ្ញាត្រូវតែបើកការស៊ើបសួរ**

ប្រសិនបើតុលាការដែលបានទទួលបណ្ដឹង តាមនីតិវិធីបង្គាប់ឱ្យបង្ហាញខ្លួនភ្លាមយល់ថាលក្ខខណ្ឌនៃមាត្រា៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌមិនបានបំពេញទេ ឬដោយសារតែភាពស្មុកស្មាញ

---

[៧៦] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៨

[៧៧] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៨

នៃរឿងក្តីដែលទាមទារជាចាំបាច់ត្រូវធ្វើការស្រាវជ្រាវបន្ថែម តុលាការត្រូវបញ្ជូនសំណុំរឿងទៅឱ្យព្រះរាជអាជ្ញាដើម្បីប្តឹងសុំឱ្យបើការស៊ើបសួរ។

ជនជាប់ចោទត្រូវនាំទៅបង្ហាញខ្លួន នៅចំពោះមុខចៅក្រមស៊ើបសួរនៅក្នុងថ្ងៃនោះតែម្តង។[៧៨] ផ្អែកតាមករណីនេះ ព្រះរាជអាជ្ញាគ្មានជម្រើសអ្វីក្រៅពីការចោទប្រកាន់បញ្ជូនសំណុំរឿងឱ្យបើកការស៊ើបសួរឡើយ។

**គ.៣.៤ អនុភាពអាចឱ្យឃុំខ្លួនបណ្តោះអាសន្ន**

ក្នុងករណីជនជាប់ចោទសុំរយៈពេលដើម្បីរៀបចំការពារខ្លួន ឬបើតុលាការយល់ថាសំណុំរឿងក្តីមិនទាន់អាចជំនុំជម្រះភ្លាមៗបានទេ នោះតុលាការត្រូវលើកពេលសវនាការទៅពេលក្រោយទៀត។ ហើយតុលាការអាចបង្គាប់ឱ្យឃុំខ្លួនបណ្តោះអាសន្នតាមសាលក្រមដែលមានសំអាងហេតុ។[៧៩]

**កថាខណ្ឌទី២. ការតម្កល់ទុករឿងឥតចាត់ការ**

ការតម្កល់រឿងទុកឥតចាត់ការគឺ ជាសិទ្ធិអំណាចថ្មីមួយដែលក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បានប្រគល់មកឱ្យតំណាងអយ្យការ។ សិទ្ធិអំណាចថ្មីនេះអនុញ្ញាតិឱ្យព្រះរាជអាជ្ញាអាចទុកចោទសំណុំរឿងក្តីព្រហ្មទណ្ឌណាមួយឥតចាត់ការបាន គឺនៅពេលដែលព្រះរាជអាជ្ញាយល់ថា ជម្រើសធ្វើការចោទប្រកាន់មិនមែនជាមធ្យោបាយដ៏ល្អនោះ។ ប៉ុន្តែមិនមែនមានន័យថាការសម្រេចមិនធ្វើការចោទប្រកាន់ចំពោះរឿងក្តីមានន័យស្មើថាជាការបញ្ចប់រឿងក្តីឡើយ។ ការតម្កល់រឿងទុកឥតចាត់ការគ្មានអាជ្ញាអស់ជំនុំទេ។ ព្រះរាជអាជ្ញានៅតែអាចសើរើកែប្រែសេចក្តីសម្រេចរបស់ខ្លួនឡើងវិញបាន ប្រសិនបើបណ្តឹងអាជ្ញាមិនទាន់ផុតរលត់នៅឡើយ[៨០]។

ទោះបីជាក្រមនីតិវិធីព្រហ្មទណ្ឌបានផ្តល់អំណាចពិសេស និងជាអំណាចឯករាជ្យដល់តំណាងអយ្យការអាចធ្វើការតម្កល់រឿងទុកឥតចាត់ការចំពោះរឿងក្តីក៏ពិតមែន ក៏ក្រមនេះបានបញ្ញត្តិអំពីករណីលើកលែងខ្លះដែលហាមឃាត់តំណាងអយ្យការធ្វើការតម្កល់រឿងទុកឥតចាត់ការផងដែរ ឧទាហរណ៍ដូចជាករណីរឿងក្តីនៃបទឧក្រិដ្ឋជាដើម ក្រមនេះបានតម្រូវជាកាតព្វកិច្ចថាតំណាងអយ្យការត្រូវតែបើកការស៊ើបសួរ[៨១]។ ម្យ៉ាងវិញទៀតក្រមនីតិវិធិព្រហ្មទណ្ឌនេះក៏បានកំណត់អំពីលក្ខខណ្ឌទម្រង់ផ្សេងៗទៀតដែលទាមទារឱ្យតំណាងអយ្យការត្រូវតែគោរពដើម្បីអាចធ្វើការតម្កល់រឿងទុកឥតចាត់ការផងដែរ។

---

[៧៨] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៣០៤

[៧៩] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៣០៤

[៨០] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤១

[៨១] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤៤

**ក. លក្ខខណ្ឌតម្កល់រឿងទុកឥតចាត់ការ**

តំណាងអយ្យការគ្មានអំណាចធ្វើការតម្កល់រឿងទុកឥតចាត់ការ ចំពោះសំណុំរឿងក្តីព្រហ្មទណ្ឌដែលខ្លួនមិនទាន់បានបើកការស៊ើបអង្កេតបឋម ឬបានធ្វើការស្រាវជ្រាវបន្ថែមឡើយ[៨២]។

សេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់តំណាងអយ្យការ ត្រូវតែផ្អែកលើសំអាងហេតុយ៉ាងច្បាស់លាស់ និងមានចង្អុលអំពីបទបញ្ញត្តិច្បាប់ដែលអនុញ្ញាតិឱ្យតំណាងអយ្យការអាចតម្កល់រឿងទុកឥតចាត់ការផងដែរ។ សេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការត្រូវធ្វើឡើងដោយដីកាសម្រេចដែលមានទម្រង់ជាលាយលក្ខណ៍អក្សរ។ ព្រោះដីកាសម្រេចនេះត្រូវធ្វើការជូនដំណឹងទៅឱ្យអ្នកប្តឹង។ ការជូនដំណឹងអំពីដីកាសម្រេចត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងខ្លីបំផុត និងយ៉ាងយូរបំផុតត្រឹមយៈពេល២ (ពីរ)ខែគិតចាប់ពីថ្ងៃចុះពាក្យប្តឹងក្នុងបញ្ជីពាក្យបណ្តឹងរបស់អយ្យការ[៨៣]។

**ខ. មូលហេតុតម្កល់រឿងទុកឥតចាត់ការ**

ជាគោលការណ៍ មុនពេលធ្វើសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់តំណាងអយ្យការត្រូវបើកការស៊ើបអង្កេតបឋម ឬធ្វើការបង្គាប់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ស្រាវជ្រាវបន្ថែម។ ក្នុងករណីសម្រេចតម្កល់រឿងទុកឥតការតំណាងអយ្យការត្រូវថ្លឹងថ្លែងទៅលើស្ថានភាព និងកាលៈទេសៈទាំងឡាយនៃការប្រព្រឹត្តបទល្មើសរបស់ជនល្មើស។

ក្នុងនាមជាអ្នកការពារផលប្រយោជន៍ទូទៅ និងជាអ្នកសម្របសម្រួលក្នុងសង្គម តំណាងអយ្យការត្រូវបានប្រគល់នូវអំណាចអាចសម្រេចមិនចោទប្រកាន់ ចំពោះបទល្មើសព្រហ្មទណ្ឌដែលខ្លួនបានទទួលឬបានដឹង វាគឺជាសិទ្ធិអំណាចដែលអាចប្រើនូវគោលការណ៍កាលានុវត្តភាពមិនចោទប្រកាន់ចំពោះបទល្មើស មានន័យថាបើបទល្មើសជាបទល្មើសមជ្ឈិមតូចតាចហើយគ្មានព្យសនកម្ម ឬមានព្យសនកម្មតិចតួចពេកនោះតំណាងអយ្យការអាចតម្កល់រឿងទុកឥតចាត់ការបាន។

ជាទូទៅការតម្កល់រឿងទុកឥតចាត់ការ ត្រូវផ្អែកលើកមូលហេតុដែលមានបញ្ញត្តិនៅក្នុងច្បាប់ជាធរមាន។ ក្នុងករណីនេះបើជនរងគ្រោះដាក់ពាក្យបណ្តឹងយឺតយ៉ាវដែលធ្វើឱ្យផុតរយៈពេលនៃអាជ្ញាយុកាលនោះតំណាងអយ្យការត្រូវតែសម្រេចតម្កល់រឿងទុកឥតចាត់ការ។

**ខ.១.១ ខ្វះធាតុផ្សំបទល្មើស**

បន្ទាប់ពីទទួលបានពាក្យបណ្តឹង ឬពាក្យបរិហារតំណាងអយ្យការត្រូវតែបើកការស៊ើបអង្កេតជាបឋម ឬស៊ើបអង្កេតបន្ថែមដើម្បីស្រាវជ្រាវស្វែងរកធាតុផ្សំនៃបទល្មើស។ ធាតុផ្សំនៃបទល្មើសមានធាតុនីត្យានុកូល ធាតុសត្យានុម័ត និងធាតុអត្តនោម័ត។ ក្នុងករណីអវត្តមានធាតុផ្សំណាមួយតំណាង

[៨២] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤០

[៨៣] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា៤១

អយ្យការគ្មានអំណាចបើការចោទប្រកាន់បានឡើយ តំណាងអយ្យការត្រូវតែសម្រេចតម្កល់រឿងទុកឥតចាត់ការ។

**ខ.១.២ សំណុំរឿងរដ្ឋប្បវេណី**

បណ្តឹងរដ្ឋប្បវេណី និងបណ្តឹងអាជ្ញាគឺជាបណ្តឹងពីរផ្សេងគ្នា។ បណ្តឹងអាជ្ញាដែលធ្វើឡើងដោយតំណាងអយ្យការមានគោលបំណងឱ្យពិនិត្យអំពីអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញអំពីពិរុទ្ធភាពរបស់ជនល្មើស និងផ្តន្ទាទោសជនដែលប្រព្រឹត្តល្មើសតាមច្បាប់។ ចំណែកឯបណ្តឹងរដ្ឋប្បវេណីវិញមានគោលបំណងឱ្យទទួលបានការជួសជុលការខូចខាតទទួលបានសំណងជម្ងឺចិត្ត។

ជនរងគ្រោះនៃអំពើល្មើស ក៏អាចធ្វើបណ្តឹងរដ្ឋប្បវេណីនៅក្នុងពេលជាមួយគ្នា និងបណ្តឹងអាជ្ញានៅចំពោះមុខសាលាជម្រះក្តីព្រហ្មទណ្ឌបានដែរ[៨៤] ក៏ប៉ុន្តែមានលក្ខខណ្ឌថាលុះត្រាតែសំណងរដ្ឋប្បវេណីនោះកើតចេញពីព្យសនកម្មនៃអំពើល្មើស។ តំណាងអយ្យការមិនចោទប្រកាន់ចំពោះអំពើណាដែលមិនមែនជាបទល្មើសព្រហ្មទណ្ឌឡើយ[៨៥]។ តំណាងអយ្យការត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការចំពោះបណ្តឹងរដ្ឋប្បវេណី ។

**ខ.១.៣ មូលហេតុមានចែងក្នុងច្បាប់**

ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧មិនបានបញ្ញត្តិអំពីមូលហេតុគតិយុត្តណាខ្លះ ដែលអនុញ្ញាតឱ្យតំណាងអយ្យការអាចតម្កល់រឿងទុកឥតចាត់ការឡើយ។ ក្រមនេះមានបញ្ញត្តិតែករណីនៃការរលត់បណ្តឹងអាជ្ញាប៉ុណ្ណោះ។ ជាភស្តុតាង យើងបានមើលឃើញនៅក្នុងមាត្រា៧(ការរលត់នៃបណ្តឹងអាជ្ញា) និងមាត្រា៨(មូលហេតុផ្សេងទៀតនៃការរលត់បណ្តឹងអាជ្ញា)ជាអាទិ៍។

ខាងក្រោមនេះ គឺជាសេចក្តីពន្យល់អំពីមូលហេតុនីមួយៗនៃការរលត់បណ្តឹងអាជ្ញា។

១- ការដកពាក្យបណ្តឹង៖

នៅក្នុងចំនុចទី២ នៃមាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានបញ្ញត្តិថាបណ្តឹងអាជ្ញាក៏អាចផុតរលត់ផងដែរដោយសារមូលហេតុនៃការដកពាក្យប្តឹង នៅក្នុងករណីដែលពាក្យប្តឹងនេះជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ជាបទព្រហ្មទណ្ឌ។

រីឯមាត្រា៨ នៃច្បាប់ស្តីពីឯកពន្ធភាពចុះថ្ងៃទី២១ ខែតុលា ឆ្នាំ២០០៦បានបញ្ញត្តិថា ព្រះរាជអាជ្ញាអាចសំរេចមិនធ្វើបណ្តឹងអាជ្ញាបានប្រសិនបើមានបណ្តឹងរបស់សហាព័ន្ធណាមួយ ស្នើសុំកុំឱ្យចោទប្រកាន់។

[៨៤] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា២២

[៨៥] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១៣៩

មាត្រាទាំងពីរនេះមានទំនាក់ទំនងគ្នា។ មាត្រា៨នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានបំពេញបន្ថែមទៅលើមាត្រា៨ នៃច្បាប់ស្តីពីឯកពន្ធភាពថាតំណាងអយ្យការអាចមិនធ្វើបណ្តឹងអាជ្ញាបើសហព័ទ្ធណាមួយប្តឹងសុំកុំឱ្យចោទប្រកាន់។ ហើយតំណាងអយ្យការត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការព្រោះមូលហេតុការរលត់បណ្តឹងអាជ្ញា។

២- ការលើកលែងទោសជាទូទៅ៖

ចំនុចទី៣ នៃមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បានបញ្ញត្តិថា ការលើកលែងទោសជាទូទៅក៏ជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញាផងដែរ។

៣- មរណភាពនៃជនល្មើស៖

ចំនុចទី១ នៃមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បានបញ្ញត្តិថា បណ្តឹងអាជ្ញាត្រូវរលត់ប្រសិនបើជនល្មើសបានទទួលមរណភាពទៅហើយ។

ដូច្នេះតំណាងអយ្យការត្រូវតែសម្រេចតម្កល់រឿងក្តីព្រហ្មទណ្ឌនោះឥតចាត់ការ។ ហើយណែនាំឱ្យជនរងគ្រោះនៃអំពើល្មើសប្តឹងទៅតុលាការរដ្ឋប្បវេណីដើម្បីទាមទារសំណងការខូចខាត និងសំណងជម្ងឺចិត្តវិញ។

៤- ការផុតអាជ្ញាយុកាល៖

ចំនុចទី២នៃមាត្រា៧នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បានបញ្ញត្តិថា បណ្តឹងអាជ្ញាត្រូវរលត់ប្រសិនបើផុតអាជ្ញាយុកាលនៃបទល្មើសទៅហើយ។

លើកលែងតែមានចែងពិសេសនៅក្នុងច្បាប់ផ្សេង ថិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញាមាន១៥(ដប់ប្រាំ)ឆ្នាំ ចំពោះបទឧក្រិដ្ឋ មាន៥(ប្រាំ)ឆ្នាំចំពោះបទមជ្ឈិម និង១(មួយ)ឆ្នាំចំពោះបទលហុ។[៨៦] ថិរវេលានៃអាជ្ញាយុកាលត្រូវចាប់ផ្តើមគិតពីពេលប្រព្រឹត្តបទល្មើស។ ប៉ុន្តែថិរវេលានេះត្រូវបានកាត់ផ្តាច់នៃគ្រប់កិច្ចនៃការចោទប្រកាន់ ឬកិច្ចស៊ើបសួរ។ ថិរវេលានៃអាជ្ញាយុកាលត្រូវផ្តើមគិតថ្មីទៅតាមរយៈពេលដែលបានវែកញែកខាងលើនៅពេលដែលបញ្ចប់កិច្ចនីតិវិធីនីមួយៗ។[៨៧]

៥- និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ៖

ចំនុចទី៤ នៃមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ បានបញ្ញត្តិថាបណ្តឹងអាជ្ញាត្រូវរលត់ប្រសិនបើបទប្បញ្ញត្តិដែលមានចែងឱ្យផ្តន្ទាទោសចំពោះបទល្មើសនោះ ត្រូវបានប្រកាសឱ្យនិរាករណ៍ហើយ។ ក្នុងករណីនេះជាសត្យានុម័តតំណាងអយ្យការត្រូវតែសម្រេចតម្កល់រឿងទុកឥតចាត់ការ។

[៨៦] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១០

[៨៧] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១១

ចំនុចទី៥ នៃមាត្រា៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បានបញ្ញត្តិថាបណ្តឹងអាជ្ញាត្រូវរលត់ប្រសិនបើអាជ្ញាអស់ជំនុំ។ អាជ្ញាអស់ជំនុំត្រូវបានឱ្យនិយមន័យថានៅពេលតុលាការសម្រេចឱ្យជនណារួចខ្លួន(លើកលែងចោទ) ជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ជាថ្មីទៀតទេចំពោះបទល្មើសដដែលនោះទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងទៀតក៏ដោយ។[៨៨]

វាមានន័យថាតំណាងអយ្យការត្រូវតែសម្រេចតម្កល់រឿងទុកឥតចាត់ការ ប្រសិនបើជនដដែលនោះធ្លាប់ត្រូវបានតុលាការប្រកាសឱ្យរួចពីបទចោទប្រកាន់ពីដំបូងហើយ ចំពោះបទល្មើសដដែលដែលគេប្តឹងសុំមកតំណាងអយ្យការឱ្យបើកការចោទប្រកាន់នោះ។

៦- ការសម្របសម្រួលជាមួយរដ្ឋ៖

ចំនុចទី១ នៃមាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បានបញ្ញត្តិថា បណ្តឹងអាជ្ញាត្រូវរលត់ប្រសិនបើមានករណីមានការសម្របសម្រួលជាមួយរដ្ឋ។

មានបទល្មើសមួយចំនួន អាចត្រូវបញ្ចប់ដោយសារតែមូលហេតុនៃការសម្របសម្រួលជាមួយរដ្ឋផងដែរ។ ឧទាហរណ៍ ៖បទល្មើសចរាចរណ៍ ។

៧- ការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល៖

ចំនុចទី៣ នៃមាត្រា៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧បានបញ្ញត្តិថា បណ្តឹងអាជ្ញាត្រូវរលត់ប្រសិនបើមានការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល។

មានបទល្មើសមួយចំនួន ត្រូវបានច្បាប់បានអនុញ្ញាតឱ្យធ្វើការបញ្ចប់សំណុំរឿងដោយគ្រាន់តែធ្វើការពិន័យ។ឧទាហរណ៍ដូចជា៖បទល្មើសព្រៃឈើ ជលផល បទល្មើសគយជាអាទិ៍។ក្នុងករណីនេះ តំណាងអយ្យការមិនអាចប្តឹងចោទប្រកាន់បានឡើយ។ តំណាងអយ្យការត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការដោយបកស្រាយលើមូលហេតុនៃការរលត់បណ្តឹងអាជ្ញា។

៨- ការមានអភ័យឯកសិទ្ធិ៖

មាត្រា ៨០ នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ បានបញ្ញត្តិថា "តំណាងរាស្ត្រមានអភ័យឯកសិទ្ធិ តំណាងរាស្ត្រណាក៏ដោយមិនអាចត្រូវបានចោទប្រកាន់ចាប់ខ្លួនឃាត់ខ្លួន ឬឃុំខ្លួនឡើយ លុះត្រាតែមានការយល់ព្រមពីរដ្ឋសភានៅក្នុងចន្លោះសម័យប្រជុំនៃរដ្ឋសភា"។

ចំពោះករណីមិនចោទប្រកាន់ចំពោះបុគ្គលដែលមានអភ័យឯកសិទ្ធិនេះ យើងអាចយល់ឃើញថាវាមិនមែនស្ថិតនៅក្នុងមូលហេតុនៃការរលត់បណ្តឹងអាជ្ញាឡើយ គឺវាគ្រាន់តែជាមូលហេតុគតិយុត្តផ្សេងទៀតដែលអនុញ្ញាតឱ្យតំណាងអយ្យការអាចសម្រេចតម្កល់រឿងទុកឥតចាត់ការប៉ុណ្ណោះ។

[៨៨] ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ មាត្រា១២

៩- ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស៖

មានមាត្រាមួយចំនួនដូចជា៖មាត្រា៣១ មាត្រា៣២ មាត្រា៣៣ មាត្រា៣៤ មាត្រា៣៥ និង មាត្រា៣៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩ ដែលបញ្ញត្តិអំពីអំពើមួយចំនួនដែលមិនអនុញ្ញាតឱ្យតំណាងអយ្យការអាចបើកការចោទប្រកាន់ចំពោះអំពើនោះឡើយ បើទោះបីជាសកម្មភាពនៃអំពើនោះត្រូវបានចាត់ទុកថាជាបទល្មើសក៏ដោយ។ ប៉ុន្តែការអនុញ្ញាតឱ្យរួចផុតពីការចោទប្រកាន់នេះមិនមែនជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញានោះទេ។ មានន័យថាលក្ខខណ្ឌដែលមានបញ្ញត្តិនៅក្នុងមាត្រាខាងលើនេះមិនត្រូវបានចាត់ជាមូលហេតុនៃការរលត់បណ្តឹងអាជ្ញាឡើយ។

**ខ.១.៤ មូលហេតុដទៃទៀត**

ព្រះរាជអាជ្ញាក៏អាចតម្កល់រឿងទុកឥតចាត់ការ ដោយផ្អែកលើមូលហេតុជាក់ស្តែងក្នុងសង្គមផ្សេងៗទៀតក្រៅការបញ្ញត្តិនៅក្នុងច្បាប់ផងដែរ។ មូលហេតុទាំងនោះមានដូចជា៖

១- ការចោទប្រកាន់មិនផ្តល់អត្ថប្រយោជន៍៖

តំណាងអយ្យការ ប្រើប្រាស់គោលការណ៍កាលានុវត្តភាពរបស់ខ្លួនចំពោះករណីនេះ។ គោលការណ៍នេះអនុញ្ញាតឱ្យតំណាងអយ្យការ មានជម្រើសមិនចោទប្រកាន់ចំពោះបទល្មើសដែលខ្លួនទទួលចាត់ការ គឺនៅពេលដែលតំណាងអយ្យការបានមើលឃើញថា ការចោទប្រកាន់មិនទទួលបានអត្ថប្រយោជន៍អ្វីឡើយ ហើយពេលខ្លះជនរងគ្រោះនៃអំពើនោះមិនទាំងបានអើពើនឹងការចោទប្រកាន់របស់តំណាងអយ្យការថែមទៀតផង។

ឧទាហរណ៍៖ ជនល្មើសបានលួចបេះស្វាយមួយផ្លែ។

២- ជម្រើសនៃការអប់រំណែនាំ៖

មានបទល្មើសមួយចំនួនតំណាងអយ្យការមិនគួរចោទប្រកាន់បញ្ជូនឱ្យស៊ើបសួរ ឬបញ្ជូនទៅជំនុំជម្រះឡើយ។ មុនពេលចោទប្រកាន់តំណាងអយ្យការ គប្បីពិនិត្យទៅលើកាលៈទេសៈនៃការប្រព្រឹត្តបទល្មើស ស្ថានភាពសង្គម ឬស្ថានភាពនៃអាយុ និងការយល់ដឹងរបស់ជនល្មើសផងដែរ។ ព្រោះថាពេលខ្លះជនល្មើសគ្មានបំណងទៅប្រព្រឹត្តបទល្មើសនោះទេ ជួនកាលដោយសារការអូសទាញពីអ្នកដទៃ ឬកើតចេញពីបរិយាកាសសង្គមមិនល្អ ដែលបានជម្រុញឱ្យគេទៅប្រព្រឹត្តបទល្មើសទាំងនោះ។

ឧទាហរណ៍៖ ករណីអនីតិជនបានប្រើប្រាស់ និងជួញដូរគ្រឿងញៀន។

តំណាងអយ្យការគួរតម្កល់រឿងទុកឥតចាត់ការចំពោះករណីនេះ ហើយបញ្ជូនអនីតិជននោះទៅឱ្យមណ្ឌលអប់រំ កែប្រែ ឬមណ្ឌលព្យាបាលគ្រឿងញៀន ដើម្បីកែប្រែខ្លួនឱ្យគាត់ក្លាយជាពលរដ្ឋល្អឡើងវិញ។

**គ. នីតិវិធីនៃការតម្កល់រឿងទុកឥតចាត់ការ**

ក្នុងករណីតំណាងអយ្យការសម្រេចតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការត្រូវបញ្ជាក់អំពីសំអាងហេតុ និងសំអាងច្បាប់ជាលាយលក្ខណ៍អក្សរនៅក្នុងដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួនហើយជូនដំណឹងអំពីដីកាសម្រេចនោះទៅឱ្យអ្នកប្តឹង នៅក្នុងរយៈពេលខ្លីបំផុតហើយយ៉ាងយូរបំផុតរយៈពេល ២(ពីរ)ខែគិតពីថ្ងៃចុះបញ្ជីពាក្យបណ្តឹង។

មុនពេលចេញដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការតំណាងអយ្យការ ត្រូវតែបើកធ្វើការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែម។

**ឃ. នីតិវិធី និងសេចក្តីសម្រេចនៃបណ្តឹងតវ៉ា**

បន្ទាប់ពីទទួលដំណឹងអំពីដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការ ប្រសិនបើអ្នកប្តឹងមិនសុខចិត្តនឹងសេចក្តីសម្រេចនោះទេ អ្នកប្តឹងអាចធ្វើបណ្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ដែលជានាយឋានានុក្រមរបស់ព្រះរាជអាជ្ញានោះបាន។

ក្នុងករណីតំណាងអយ្យការទទួលបានពាក្យប្តឹងតវ៉ា ចំពោះសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការរបស់ខ្លួន តំណាងអយ្យការត្រូវធ្វើលិខិតជូនដំណឹងមួយទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ឱ្យបានដឹងអំពីការប្តឹងតវ៉ានេះដោយមានរៀបរាប់អំពីសំអាងហេតុ និងសំអាងច្បាប់ដែលខ្លួនសម្រេចតម្កល់រឿងទុកឥតចាត់ការ។

ការតវ៉ាត្រូវធ្វើនៅក្នុងរយៈពេល២(ពីរ)ខែគិតពីថ្ងៃទទួលដំណឹង អំពីសេចក្តីសម្រេចតម្កល់រឿងទុកឥតចាត់ការ។ ការតវ៉ានេះត្រូវធ្វើតាមបណ្តឹងសាមញ្ញនៅអង្គការអយ្យការដែលពាក់ពន្ធ័។ បន្ទាប់មកសំណុំរឿងត្រូវបញ្ជូនភ្លាមទៅឱ្យសាលាឧទ្ធរណ៍ ដែលមានសមត្ថកិច្ចដែនដីលើអយ្យការអមសាលាដំបូងនោះ។

ប្រសិនបើយល់ឃើញថា ការតវ៉ានោះមានមូលហេតុត្រឹមត្រូវអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍អាចចេញអធិបញ្ជាដល់ព្រះរាជអាជ្ញាអមសាលាដំបូងឱ្យធ្វើការចោទប្រកាន់។ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ធ្វើអធិបញ្ញាតាមការណែនាំជាលាយលក្ខណ៍អក្សរ។

ផ្ទុយទៅវិញ ប្រសិនបើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍យល់ឃើញថាការតវ៉ានោះគ្មានមូលហេតុត្រឹមត្រូវទេ អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍សម្រេចតម្កល់សេចក្តីសម្រេចរបស់ព្រះរាជអាជ្ញាអមសាលាដំបូងទុកជាបានការហើយជូនដំណឹងអំពីសេចក្តីសម្រេចនេះដល់អ្នកប្តឹងតវ៉ា។

# សេចក្តីសន្និដ្ឋាន

តាមរយៈលទ្ធផលនៃការស្រាវជ្រាវលើទ្រឹស្តីគតិយុត្ត ចំពោះប្រធានបទ"ចំណាត់ការលើសំណុំរឿងស៊ើបអង្កេតរបស់ចៅក្រមអយ្យការ" នេះរួចមកបានបង្ហាញឱ្យយើងមើលឃើញថាការជ្រើសរើសជម្រើសណាមួយចំពោះ ចំណាត់ចាត់ការរឿងក្តីរបស់ព្រះរាជអាជ្ញាគឺមិនមែនជារឿងងាយស្រួលនោះទេ។ ការប្តឹងចោទប្រកាន់ ឬការតម្កល់រឿងទុកឥតចាត់ការ គឺជាវិញ្ញាសារដែលស្មុគស្មាញមួយដែលតំណាងអយ្យការត្រូវថ្លឹងថ្លែងឱ្យបានម៉ត់ចត់បំផុតនៅមុនពេលធ្វើសេចក្តីសម្រេចណាមួយ។ ការសម្រេចចិត្តប្តឹងសុំចោទប្រកាន់របស់តំណាងអយ្យការ មានអានុភាពដាក់ឱ្យស្ថិតក្រោមការពិនិត្យអំពីបទល្មើសចំពោះបុគ្គលណាម្នាក់ ឬច្រើននាក់ មានអានុភាពផ្លាស់ប្តូរឋានៈរបស់បុគ្គលដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរឱ្យក្លាយទៅជាជនត្រូវចោទ ឬអាចមានអានុភាពដកហូតនូវសិទ្ធិសេរីភាពរបស់ជននោះផងដែរ។ រូបភាពនៃការដកហូតសិទ្ធិសេរីភាពទាំងនោះអាចជាការឃុំខ្លួនបណ្តោះអាសន្ន ឬការដាក់ឱ្យស្ថិតក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការជាដើម។ អាជ្ញាហើយពេលខ្លះបានបណ្តាលឱ្យមានភាពអយុត្តិធម៌ដល់ជនរងគ្រោះផងដែរ។

ដើម្បីកាត់បន្ថយវិបត្តិដែលកើតពីការសម្រេចចិត្តទាំងនេះនីតិករបាន បង្កើតនូវលក្ខខណ្ឌជាច្រើនដែលតម្រូវឱ្យតំណាងអយ្យការត្រូវតែគោរពជាចាំបាច់ ចំពោះចំណាត់ការលើរឿងក្តីរបស់ខ្លួន។ដូចយើងបានមើលឃើញនៅក្នុងកថាខណ្ឌទី២ នៃមាត្រា២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ញត្តិថា "មុននឹងសម្រេច (តម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើស) តំណាអយ្យការបើកការស៊ើបអង្កេតបឋម ឬបង្គាប់ឱ្យធ្វើការស្រាវជ្រាវបន្ថែមសិន។ មិនតែប៉ុណ្ណោះក្រមនីតិវិធីព្រហ្មទណ្ឌនេះ ក៏ថែមទាំងបានបង្កើតនូវលក្ខខណ្ឌជាទម្រង់ និងចែងជាមូលហេតុចាំបាច់មួយចំនួនទៀតជូនតំណាងអយ្យការ ដើម្បីជាជំនួយក្នុងការសម្រេចចិត្តធ្វើការតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ផងដែរ។

ជាសរុបមក ក្នុងនាមជាម្ចាស់បណ្តឹងអាជ្ញា ជាអ្នកបំរើឱ្យផលប្រយោជន៍ទូទៅការពារផលប្រយោជន៍សង្គម តំណាងអយ្យការត្រូវបំពេញការងារដោយការតាំងចិត្តខ្ពស់ ដោះស្រាយឱ្យបានរាល់ចំណុចអសកម្មទាំងឡាយ ទោះបង្កើតឡើងដោយសារបញ្ហាផ្នែកបច្ចេកទេសក្តី បញ្ហាថវិការក្តី ឬកើតចេញពីបញ្ហារបស់បុគ្គលដែលអនុវត្តច្បាប់ក្តីក្នុងឆន្ទៈស្វែងរកយុត្តិធម៌ជូនជាតិមាតុភូមិ។

# អនុសាសន៍

យ៉ាងណាមិញ ទោះបីជាសិក្សាលើទ្រឹស្តីគតិយុត្តមានការលំបាក និងជួបប្រទះនូវបញ្ហាខ្លះក៏ដោយក៏ខ្ញុំនៅតែជឿរជាក់ថា ប្រសិនបើអ្នកអនុវត្តច្បាប់ទាំងអស់ចូលរួមសាមគ្គីគ្នា ក្នុងឆន្ទៈបម្រើវិស័យយុត្តិធម៌ និងប្រជុំពិភាក្សាគ្នាក្នុងឆន្ទៈដោះស្រាយបញ្ហានោះពិតជាអាចដោះស្រាយឧបសគ្គទាំងឡាយបានជាក់ជាមិនខាន ហើយនៅពេលនោះភាពអយុត្តិធម៌នឹងកាត់បន្ថយហើយស្តែងឡើងជាសត្យានុម័ត ។

ដើម្បីចូលរួមចំណែកក្នុងការធ្វើសេចក្តីសម្រេចចិត្តឱ្យបានល្អប្រសើរ ប្រកបទៅដោយភាពយុត្តិធម៌ យើងខ្ញុំសូមជូននូវយោបល់ខ្លះៗចំពោះការបំពេញការងាររបស់តួអង្គតំណាងអយ្យការដូចតទៅ៖

១ នៅគ្រប់ពេលដែលធ្វើចំណាត់ការសំណុំរឿងព្រហ្មទណ្ឌដែលអាចជាសម្រេចធ្វើការចោទប្រកាន់ ឬ សម្រេចតម្កល់រឿងទុកឥតចាត់ការ តំណាងអយ្យការត្រូវធ្វើសំអាងហេតុ និងសំអាងច្បាប់អោយច្បាស់លាស់ដែលជាមូលហេតុនាំឱ្យខ្លួនសម្រេចដូច្នេះ។

២ ត្រូវបំពេញការងារដោយផ្អែកលើគោលការណ៍នៃគតិទាំងប្រាំគឺ វិរិយសម្បយុត្ត សុចរិតយុត្តិធម៌ បញ្ញត្តិគារវោ សមទណ្ឌោ បញ្ញាវុធវិនិច្ឆ័យ។

៣ អានុភាពនៃដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួររបស់តំណាងអយ្យការ អាចនាំឱ្យមានការឃុំខ្លួនបណ្តោះអាសន្ន គឺជាការដកហូតសេរីភាពរបស់បុគ្គល ដូច្នេះគប្បីតំណាងអយ្យការត្រូវធ្វើការស៊ើបអង្កេតអោយបានល្អិតល្អន់ជៀសវាងមានការបំពានសិទ្ធិរបស់បុគ្គល។

៤ តំណាងអយ្យការគួរតែមានទំនាក់ទំនងល្អជាមួយនគរបាលយុត្តិធម៌ ឬមន្ត្រីសាធារណៈដទៃទៀតដើម្បីធានាដល់ការសម្របសម្រួលដល់ការធ្វើ ចំណាត់ការសំណុំរឿងព្រហ្មទណ្ឌរបស់ខ្លួនប្រកប ដោយប្រសិទ្ធភាពខ្ពស់។

៥ សេចក្តីសម្រេចត្រូវផ្អែកលើបទប្បញ្ញត្តិដែលមានចែងក្នុងច្បាប់ ដោយបញ្ជាក់សំអាងហេតុដែលជាមូលហេតុនាំខ្លួនធ្វើសេចក្តីសម្រេចដូច្នេះ ឱ្យបានច្បាស់លាស់ដោយធ្វើយ៉ាងណាឱ្យភាគីនៃរឿងក្តីដែលខ្លួនកំពុងចាត់ការមានសេចក្តីអស់ចិត្ត និងយល់ស្របចំពោះការសម្រេចរបស់ខ្លួន។

៦ តំណាងអយ្យការត្រូវប្រកាន់ភ្ជាប់នូវគោលការណ៍ស្មើភាព ដើម្បីស្វែងរកយុត្តិធម៌ជូនប្រជាពលរដ្ឋព្រោះតំណាងអយ្យការ ជាបុគ្គដែលតំណាងអោយផលប្រយោជន៍សាធារណៈ និងត្រូវការពារផលប្រយោជន៍របស់ប្រជាពលរដ្ឋជៀសវាងមាន ការបំពានសិទ្ធិប្រជាពលរដ្ឋតាមគ្រប់រូបភាព។